PRIMERICA
A Citi Company
Chanthy Sek & Shawn Dougherty
Bus: 1-866-582-3172
Cell: 267-984-8554
Life Insurance
Car Insurance
Refinance Your Debts
Investments
Office or Home Appointment
We also provide translation and interpretation services.
E-mail: 8665823172@primerica.gosolo.com
Primerica Financial Services. 1035 Virginia Dr., Ste 100H. Ft. Washington, Pa 19034

# ខ្មែរប៉ុស្តិ៍
# The Khmer Post
ISSUE 38 16th- 30th June 2009

SUNSHINE JEWELRY INC
Fine Jewelry
Certified Diamonds & Custom Design
702 Washington Avenue
Philadelphia, Pa 19147
Phone: (215) 271-2950
Fax: (215) 271-2962
Email: colorofsunshine@yahoo.com

# ចលនាប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរ



ដោយ : ពិន សំខុន

●●●ទីក្រុងហ្វីឡាដែលហ្វីយ៉ា បានទទួលកិត្តិយសជាទីក្រុងដែលគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សនៃកម្ពុជាធ្វើសេចក្តីប្រកាសជាលើកដំបូងបង្អស់នូវសម្ព័ន្ធភាពសម្រាប់រួបរួមគ្នាជាអង្គការមួយសម្រាប់បោះឆ្នោតសកល· នាឆ្នាំ២០១៣ ខាងមុខ ។ លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី និងលោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស បានមកជួបគ្នានៅភោជនីយដ្ឋានមួយចំពោះមុខសហគមន៍ខ្មែរប្រមាណ២០០នាក់ កាលពីរាត្រីថ្ងៃសុក្រ ទី១២ ខែមិថុនា ឆ្នាំ២០០៩ ដើម្បីធ្វើសេចក្តីប្រកាសម្អាក់ម្តងអំពីវត្ថុបំណងនៃចលនារួមរបស់ខ្លួនឈ្មោះ " ចលនាប្រជាធិបតេយ្យដើម្បីផ្លាស់ប្តូរ " ។

ពីទីក្រុងនៃរដ្ឋផែនស៊ីវេនា ដែលល្បីឈ្មោះ ដោះសារតែជារដ្ឋដែលបានទទួលឯករាជ្យមុនគេនៃ ស.រ.អា គេរំពឹងថា មេគណបក្សខ្មែរទាំងពីរ និងដឹកនាំការតស៊ូស្របច្បាប់ យកជ័យជំនះជូនឯករាជ្យភាពទៅដល់ពលរដ្ឋខ្មែរ ដែលប្រកបដោយសំណាងល្អ ។

តទៅនេះជាសេចក្តីថ្លែងការណ៍របស់មេដឹកនាំនៃគណបក្សប្រឆាំងទាំងពីរ : (តទៅទំព័រទី ០៩)

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ_អង្គរ
Angkor International Travel Agency
World Wide Travel & Tour Services
Cambodia – Vietnam – Laos – Thailand
(Since 1991)
USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
Cambodia: Victory Travel
No. 96 Eo Street. 148, Phsar Kandal
Phnom Penh, Cambodia
Tel: 011-892329
Manager SIN PO
CHENDA: 023-221069
Serving all Major air lines :
. SINGAPOR
. EVA AIR
. KOREAN AIRLINES
. MALAYSIA etc...

Professional Construction Services
Subcontract
COMMERCIAL - RESIDENTIAL
Tony Dung
267-506-9784 ~ 215-667-4893
2844 S. Randoph St., Philadelphia, PA 19148
Remodeling and Basement
In & Out of the House
Paint Inside & Outside Any House
Hardwood Floors
Cleaning Any Floors & Renew
Siding, Power Wash

Mobile-net
We connect you to the world!
Since 1995
6.9¢
កម្ពុជា
1.9¢
5.5¢
my011.com
1(800) 818-9000

# បទសម្ភាសន៍ជាមួយតំណាងរាស្ត្រខ្មែរ

ដោយ : ថាច់ សុបិន

❖❖❖ នៅទីស្នាក់ការសាខាគណបក្សសិទ្ធិមនុស្ស នៅហ្វីឡាដែលហ្វីយ៉ា មានការជួបប្រជុំគ្នា នាថ្ងៃទី៧ ខែ មិថុនា ដើម្បីទទួលសមាជិកសភាខ្មែរពីររូប គឺលោក កឹម សុខា និងលោក យែម បុណ្ណារិទ្ធ ដែលជាប្រធាន និងអគ្គលេខាគណបក្សដដែល ។



លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស

**សុបិន ថាច់** ខ្មែរប៉ុស្តិ៍បានសាកសួរជូនព័ត៌មាននាពេលនោះ :

១-បទសម្ភាសន៍ជាមួយលោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស

**សំនួរ សុបិន ថាច់ :** លោកបានផ្តល់កំណត់ពេលថា នឹងមកហ្វីឡាដែលហ្វីយ៉ា នៅសប្តាហ៍ក្រោយទេ តែហេតុអ្វីក៏លោកបែរជាមកដល់នៅមួយអាទិត្យមុនទៅវិញ ?

**ចម្លើយ កឹម សុខា :** ខ្ញុំមកពេលនេះ គឺខ្ញុំចង់មកចូលរួមកម្មវិធីរបស់បងប្អូនខ្មែរក្រោម ដែលកំពុងរៀបចំរំលឹកខួបទី ៦០ ឆ្នាំ ដែលបារាំងបានប្រគល់ទឹកដីកម្ពុជាផ្នែកខាងត្បូងឱ្យទៅយួនកាន់កាប់ ទុក្ខរបស់ខ្មែរក្រោម គឺជាទុក្ខរបស់ខ្មែរគ្រប់រូប ហើយមានទាំងរូបខ្ញុំផងដែរ ។

**សំនួរ :** ចលនាខ្មែរក្រោមមានពីរ-បី តើលោកយល់ថា ចលនាមួយណាដែលមានផលប្រយោជន៍សំរាប់គណបក្សសិទ្ធិមនុស្ស ?

**ចម្លើយ :** គឺបញ្ហាអធិបតេយ្យភាព បូរណភាពទឹកដី មានសារៈសំខាន់ណាស់ បើជាតិសាសន៍គ្មានទឹកដីហើយ គឺពុំមានសេចក្តីថ្លៃថ្នូរទេ ការតស៊ូ គឺស្ថិតនៅលើមូលដ្ឋានសំខាន់ ទី១ គឺដើម្បីជីវភាពថ្លៃថ្នូររបស់ពលរដ្ឋ ។

**សំនួរ :** ចលនាខ្មែរក្រោមចំពោះទឹកដី មានបេសកកម្មខុសៗគ្នា ដូចជា ក្រុមមួយនោះ គេជ្រើសយកការប្រយុទ្ធដើម្បីសិទ្ធិមនុស្សនៅកម្ពុជាក្រោម ក្រុមមួយទៀត គេបង្កើតកងទ័ពដើម្បីរំដោះ នឹងក្រុមមួយទៀតនោះ នៅស្រុកខ្មែរ គេថា ទាមទារសិទ្ធិមនុស្សផង បង្កើតកងទ័ពផង តើលោកជ្រើសយកមួយណា ?

(តទៅទំព័រទី ០៤)






វិចារណកថា

# ថ្នាក់ដឹកនាំ

***ដោយ : ពិន សំខុន***

●●●ក្នុងខែ មិថុនា នេះ ហ្វីឡាដែលហ្វីយ៉ា បានទទួលថ្នាក់ដឹកនាំខ្មែរជាច្រើនទៅទីក្រុងរបស់ខ្លួន មានលោកឯកអគ្គរាជទូតខ្មែរប្រចាំទីក្រុងវ៉ាស៊ីនតុន ស.រ.អា លោក ហែម ហេង មានលោកឯកអគ្គរាជទូតខ្មែរប្រចាំអង្គការសហប្រជាជាតិ លោក សៀ កុសល មានប្រធានគណបក្សសិទ្ធិមនុស្សលោក កឹម សុខា ដែលជាសភាតំណាងរាស្ត្រខ្មែរ មានលោក សម រង្ស៊ី ដែលជាសភាតំណាងរាស្ត្រខ្មែរដ៏ល្បីល្បាញជាងគេថាជាតំណាងរាស្ត្រគណបក្សប្រឆាំង និងជាប្រធានគណបក្ស សម រង្ស៊ី ផងដែរ ។ ថ្នាក់ដឹកនាំអញ្ជើញមកឱ្យកិត្តិយសសហគមន៍ខ្មែរនៅហ្វីឡាដែលហ្វីយ៉ាយ៉ាងសន្ទឹកសន្ទាប់យ៉ាងនេះ តើមានបានធ្វើឱ្យភ្ញាក់ផ្អើលដល់ម្ចាស់សហគមន៍ដែលបើកភ្នែកសម្លឹងភ្លឹស១យ៉ាងស្ញៀមស្ងាត់នោះបានដែរឬទេ ? តើថ្នាក់ដឹកនាំ បានន័យថាយ៉ាងដូម្តេច?

គេតែងតែហៅកាលពីជំនាន់មុនកុម្មុយនីសថា ជា"មេដឹកនាំ"ឬក៏"មគ្គុទេសន៍" ឬ "អគ្គមគ្គុទេសន៍" ដែលសំដៅមនុស្សម្នាក់ជាឯកជន ដែលបញ្ជា ឬមានឥទ្ធិពលអាចប្រើអ្នកដ៏ទៃទៀតបាន។ ក្រោយជំនាន់កុម្មុយនីសមកពាក្យនេះក៏ក្លាយទៅជា "ថ្នាក់ដឹកនាំ" ដែលជាក្រុម ឬស្រទាប់មនុស្សដែលនៅក្នុងឋានៈជាកំពូល សំរាប់ណែនាំ ឬដឹកនាំអ្នកដ៏ទៃឱ្យដើរតាម ។ អ្នកទាំងនោះបានទទួលស្គាល់ពីស្ថាប័នណាមួយរបស់រដ្ឋ ឬរបស់ការរួមប្រជុំមនុស្សជាសហគមន៍ ហើយដើរតួជាតំណាងរបស់ស្ថាប័នរដ្ឋនោះ ឬសហគមន៍នោះទៅ ។ ជាទូទៅគុណសម្បត្តិអ្នកទាំងនោះ គឺវាស់ដោយកំពស់នៃការសិក្សា ស្នាដៃ ដែលបានធ្វើឱ្យប្រសើរជូនរដ្ឋ ឬសហគមន៍ គុណសម្បត្តិសីលធម៌ផ្ទាល់ ហើយនិងការប្រកួតឈ្នះ ហើយទទួលការទុកចិត្តច្រើនពីនាយចៅហ្វាយ ឬពីសមាជិកសហគមន៍ ។ បើកាលពីមុនជំនាន់បារាំងកាន់កាប់កម្ពុជា "មេដឹកនាំ" គឺជាបណ្តាមនុស្សដែលមានកម្លាំង ប្រាជ្ញា ចេះបំរើចៅហ្វាយយ៉ាងស្មោះស្ម័គ្រ ឬជាកន្សែសាលោហិតជិតឆ្ងាយរបស់ព្រះរាជវង្ស ដែលបានក្លាយជាស្វ័យប្រវត្តិ ជា "មេដឹកនាំ" ដោយគ្មានគូប្រជែង តែដល់ក្រោយមកទើបបារាំងបញ្ចេញច្បាប់ ឱ្យមានការជ្រើសរើសក្នុងបណ្តាអ្នកពូកែ អ្នកមានប្រាជ្ញា មានទេពកោសល្យឱ្យមកបំរើការងាររបស់រដ្ឋ ឬការងាររបស់ស្តេចជាម្ចាស់ផែនដី... រហូតដល់ការដាក់ឱ្យប្រើការបោះឆ្នោតសាកល ដើម្បីជ្រើសរើសមនុស្សដ៏ឆ្នើមបំផុត គេឱ្យមកកាន់ការងាររបស់ប្រជាជាតិ ។ មានស្ត្រីចំនួនតិចតួចណាស់ ដែលមានភាពជា "មេដឹកនាំ" ដោយសារវប្បធម៌តាំងពីសម័យមហានគរ សម័យអង្គរ ស្ត្រីភេទបានត្រូវចាត់ទុកជាភេទទន់ខ្សោយ ភេទបន្ទាប់សន្សំ នៃវប្បធម៌ឥទ្ធិពលឥណ្ឌា ក៏ប៉ុន្តែវប្បធម៌ខ្មែរមុនពួកឥណ្ឌាមកដល់ គឺស្ត្រីសោះដែលជា "មេដឹកនាំ "។ ពាក្យ "មេ" សំដៅទៅរកស្ត្រីភេទ ដែលកាលពីសម័យព្រះនាងសោមា រហូតមកដល់សព្វថ្ងៃនៅសល់ឫសគល់នៃពាក្យ"មេទ័ព"-"មេស្រុក"-"មេឃុំ"-"មេមុនបា"-"យាយមុនតា"-"មេកន្ទ្រាញ" គឺស្ត្រីមានតួនាទីដឹកនាំសំខាន់ជាងប្រុស រហូតដល់វប្បធម៌អនុញ្ញាតិឱ្យស្ត្រីជាអ្នកចូលស្តីដណ្តឹងប្រុសណាដែលគេស្រឡាញ់មកធ្វើជាប្តីទៀតផង ។ គុណសម្បត្តិដែលធ្វើជា "មេដឹកនាំ" បានប្តូរពីស្ត្រីទៅប្រុសនាទសវត្សរ៍ទី៣ ហើយប្តូរពីកម្លាំងដែលចេះច្បាំងនឹងប្រើយុទ្ធសិល្ប៍មកចំណេះដឹងនៃប្រាជ្ញា ចាប់ពីសតវត្សទី១៩ បន្ទាប់ពីបារាំងចូលមកដល់ ។ តែចំពោះប្រាជ្ញានេះ ក៏ពុំបាននៅស្ថិតស្ថេរប៉ុន្មានទេ ដោយសារបរិយាកាសនៃសេរីភាពពេញលេញ ពុំបានកើតឡើង ហើយមកដល់ជំនាន់កុម្មុយនីសទៀតសោត ពួកអ្នកនយោបាយ "ខោខ្មៅស្បែកជើងកង់ឡាន" បានរំលាយចំណេះមកដល់ចំណុចសូន្យមកវិញយ៉ាងរលីង។ ទើបតែឆ្នាំ ១៩៩៣ មកទល់សព្វថ្ងៃនេះទេ ទើបន័យនៃ "មេដឹកនាំ" បានប្រែបន្តិចម្តង មកជាអ្នកមានចំណេះមានទេពកោសល្យចេះយកអាសារអ្នកដ៏ទៃ...មកវិញ។ តែគេនៅតែឆ្ងល់នៅឡើយអំពីអត្ថន័យនៃ "មេដឹកនាំ" ខ្មែរ ដែលនៅធ្វើឱ្យគេស្រពិចស្រពិលពីគុណភាពនៃអ្នកទាំងឡាយនោះ ដែលបានក្លាយទៅជា "ថ្នាក់ដឹកនាំ" វិញទៅហើយក៏ដោយ ។



លោក ពិន សំខុន

នៅ ស.រ.អា នេះ មាន "មេដឹកនាំ" បន្តបន្ទាប់គ្នាជាច្រើនមកហើយ ដែលបានបង្ហាញថាបានធ្វើឱ្យប្រជាពលរដ្ឋភ្ញាក់ផ្អើល រំជើបរំជួលដោយសារតែការដឹកនាំរបស់គេ : រ៉ូណាល រ៉េក្កាន់-គ្លីនតុន-ជច ប៊ូស ចុងក្រោយនេះ បារ៉ាក់ អូបាម៉ា...សុទ្ធតែត្រូវបានក្រុមមនុស្សមិនត្រឹមតែអាមេរិកាំង គឺមនុស្សទាំងសកលលោកបានវាយតម្លៃថា ជា"មេដឹកនាំ" ពិតប្រាកដ ។

(តទៅទំព័រទី ១៥)


**BALDI FUNERAL HOME**

1331 S. Broad St. Philadelphia, Pa 19147

Cell: 267-934-9888 / Tel : 215-389-2414

**សូមសួររកលោក សេង** ឬ Thomas

**ឈាបនកិច្ចតាមប្រពៃណី**

ឈាបណដ្ឋានមានផ្តល់ជូននូវក្តារមឈូស ទីធ្លាសំរាប់បញ្ចុះ រៀបកំរងផ្កា និងសេវាឈាបណកិច្ចច្រើនប្រភេទ តម្លៃទៅតាមប្រភេទដែលត្រូវការសេវាឈាបណកិច្ចតាមវប្បធម៌ និងតាមសាសនា និងបំពេញជូនជាកិត្តិយស យើងនឹងខំឱ្យអស់ពីសមត្ថភាព ដើម្បីបំពេញសេចក្តីត្រូវការ និងបំពេញប្រាថ្នារបស់លោកអ្នក ។

**ពិធីបូជាសព**

"បាល់ឌី" ផ្តល់ជូននូវពិធីបូជាសពគ្រប់បែបជម្រើសរាប់ទាំងឱ្យភ្លើង ក្តារមឈូសសំរាប់សពទន្ទឹមនោះ មានសេវាពិធីបុណ្យតាមវប្បធម៌ ការតម្កល់អដ្ឋិធាតុជាចុងបញ្ចប់។ មានជួយធ្វើលិខិតក្នុងករណីចង់នាំអដ្ឋិធាតុទៅកាន់ប្រទេសមួយទៀត មានចារឈ្មោះសពនៅលើទំព័រ"ខ្មែរប៉ុស្តិ៍" ជូនផង ។





**(Locates in South Philly, convenience traffic, and free parking)**

**Traditional Funeral**

Funeral Home provides caskets, cemetery space, floral arrangements, and funeral service options in various price ranges. Cultural and Religious funeral service is honored. We put full efforts to meet your needs and fulfill your wishes.

**Cremation**

Baldi offers complete cremation options including a combustible casket for the body, on site performing cultural memorial service, final placement of the cremated remains, paperwork assistance in case that need to transport the cremated remains to another country, and the Khmer Post newspaper notices.

# ទស្សនៈវិស័យ: សេចក្តីទុក្ខលំបាកនៃជនចាស់ជរា

***ដោយ : ម៉ម យីន***

●●●មនុស្សគ្រប់រូប ដែលបានចាប់បដិសន្ធិកើតមក ហើយមានជីវិតរស់នៅលើផែនដីនេះ តែងតែប្រកបដោយវ័យបីជាមូលដ្ឋាន គឺវ័យទី១ ហៅថា បឋមវ័យ ទី២ មជ្ឈិមវ័យ និងទី៣ បច្ឆិមវ័យ ឬហៅថា វ័យកុមារភាព វ័យយុវភាព និងវ័យជរាភាព ។

បឋមវ័យ ឬវ័យកុមារភាព ចាប់តាំងពីថ្ងៃប្រសូត្រកើតមកដល់អាយុ ១៣ ឆ្នាំ គឺជាជីវិតរស់នៅក្រោមការបីបាច់ថែរក្សារបស់ឪពុកម្តាយ ជាអ្នកអាណាព្យាបាលទាំងស្រុង ។

មជ្ឈិមវ័យ ឬវ័យយុវភាពចាប់ពីអាយុ ១៤ ឆ្នាំ ទៅដល់ ១៩ ឆ្នាំ គឺជាជីវិតរស់នៅដោយនៅតែពឹងផ្អែកទៅលើឪពុកម្តាយ ខ្លះចិញ្ចឹមជីវិតខ្លួនឯងខ្លះបានផ្សំគ្នាជាមួយការអភិវឌ្ឍន៍ចំរើនឡើងខាងកម្លាំងកាយ រូបរាងកាយ និងចិត្តគំនិត ដែលមនុស្សម្នាក់ៗត្រូវតែមាន ។ ជាពិសេសនៅក្នុងវ័យយុវភាពនេះ មនុស្សកំពុងស្ថិតក្នុងជីវិតប្រកបដោយថាមពលទាំងកាយទាំងចិត្តយ៉ាងសប្បាយរីករាយ និងសុភមង្គលបំផុត ។

លុះចូលមកដល់វ័យចាស់ជរា គឺជាវ័យចុងក្រោយដែលមនុស្សម្នាក់ត្រូវតែទទួលយក ដោយជៀស គេចវេស ទៅណាពុំរួចសោះឡើយ ។

សភាពជីវិតរស់នៅក្នុងវ័យចាស់ជរានេះ ទោះបីចាស់ជរានេះ មានទ្រព្យ មានចំណេះវិជ្ជាខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ក៏នៅតែមានទុក្ខលំបាកមកគ្របដណ្តប់លើរូបកាយ និងចិត្តអារម្មណ៍ ពីព្រោះនៅក្នុងវ័យនេះ អ្វីដែលធ្លាប់មាននៅក្នុងវ័យទាំងពីរខាងដើម បានរសាត់ចេញពីរាងកាយ និងចិត្ត អារម្មណ៍ទៅបន្តិចម្តងៗ សភាពទ្រុឌទ្រោម ថមថយកម្លាំងកាយ និងកម្លាំងចិត្ត បានធ្លាក់ចុះបន្តិចម្តងៗ ជម្ងឺ រោគាព្យាធិបានលេចចេញមកនៅក្នុងសរិរៈរាងកាយ ដែលបណ្តាលឱ្យត្រូវតែមានសេចក្តីត្រូវការជាចាំបាច់បំផុតនូវអ្នកជំនួយជួយបីបាច់ថែរក្សា ទាំងផ្លូវកាយទាំងផ្លូវចិត្ត ។

បើសិនណាជាមនុស្សណា បានរៀបចំជីវិតខ្លួនបានល្អប្រសើរ ដោយសារខិតខំស្វែងរកលុយកាក់ ទ្រព្យសម្បត្តិបានច្រើនស្តុកស្តម្ភនោះ គឺជាការប្រសើរដែរ ពីព្រោះដល់ពេលខ្លួនចាស់ជរាទៅអាចយកលុយ និងទ្រព្យសម្បត្តិមកធ្វើជាមធ្យោបាយសំរាប់ជួយដោះស្រាយបញ្ហានានាក្នុងវ័យចាស់ជរានោះ ប៉ុន្តែបើគ្មានលុយកាក់ទ្រព្យសម្បត្តិទេ គឺសេចក្តីទុក្ខលំបាកខាងផ្លូវចិត្តផ្លូវអារម្មណ៍ និងផ្លូវកាយដែរ ដែលគ្រប់ពេលវេលាជនចាស់ជរា ត្រូវតែទទួលសម្ពាធពីខាងក្រៅគ្រប់បែបយ៉ាង រហូតធ្វើឱ្យមនុស្សនោះ ទៅជាវង្វេងវង្វន់ ខូចសតិ បាត់បង់នូវការចងចាំស្ទើរអស់រលីង បណ្តាលឱ្យជនចាស់ជរារបៀបនេះមានសេចក្តីទុក្ខលំបាកខ្លាំងណាស់ ទំរាំដល់ថ្ងៃអស់ជន្មាយុលាចាកលោកនេះទៅ ។

ដោយមើលឃើញសេចក្តីទុក្ខលំបាកវេទនានៃមនុស្សចាស់ជរា ទាំងប្រុសទាំងស្រី ទាំងមានទាំងក្រនេះហើយ ទើបបណ្តាលឱ្យមេដឹកនាំប្រទេសនិមួយៗ នៅក្នុងពិភពលោក ត្រូវតែខិតខំរិះរកបង្កើតគម្រោងការ និងកម្មវិធីជាមនុស្សធម៌ជួយឧបត្ថម្ភ គាំពារគ្រប់បែបយ៉ាងដល់មនុស្សចាស់ជរាឱ្យបានទទួលការបន្ធូរបន្ថយនូវសេចក្តីទុក្ខលំបាកវេទនាខ្លះ ខាងផ្លូវកាយ និផ្លូវចិត្ត ។

ប៉ុន្តែគេនៅមានឃើញ ប្រទេសមួយចំនួនមានមនុស្សចាស់ជរាស្ទើរ ទូទាំងប្រទេសកំពុងរស់នៅមានជីវិតសែនទុក្ខលំបាកគួរឱ្យអាណិតអាសូរខ្លាំងណាស់ ពីព្រោះរដ្ឋអំណាចពុំបានចែករំលែកនូវមូលនិធិជាតិមួយផ្នែក ដែលអាចធ្វើបានយកទៅជួយឧបត្ថម្ភផ្គត់ផ្គង់ដល់ជនចាស់ជរា ដែលជាជនក្រីក្រគ្មានកូនចៅ ឬញាតិសន្តានជាទីពឹងពុំនាក់ ធ្វើឱ្យជីវិតជនចាស់ជរារស់នៅតាមយថាកម្មរបស់ខ្លួន ។

នៅពេលណាមេដឹកនាំប្រទេស បានចាប់អារម្មណ៍ និងយកចិត្តទុកដាក់ខ្លាំងក្លាមែនទែន ហើយរដ្ឋមានគម្រោងធ្វើកម្មវិធី ដើម្បីផ្តល់មូលនិធិ និងមធ្យោបាយ ម្ហូបអាហារ ការថែរក្សាសុខមាលភាព រួមទាំងសេវាកម្មដទៃទៀត ដែលជាគុណប្រយោជន៍ដល់មនុស្សចាស់ជរា ដោយធ្វើការណែនាំនៅក្នុងសហគមន៍នៃសង្គមជាតិ ហើយបង្កើនជាអង្គការ សមាគម សហការណ៍គ្នាឡើងឱ្យមានឱកាសល្អ យកមូលនិធិ និងមធ្យោបាយទាំងអស់នោះ មកបំរើ ជួយឧបត្ថម្ភបីបាច់ថែរក្សា សម្រាលសេចក្តីទុក្ខវេទនាដល់មនុស្សចាស់ជរាទាំងអស់ ដែលកំពុងជួបប្រទះនូវបញ្ហាក្នុងជីវិតជារៀងរាល់ថ្ងៃ ។

ក្នុងចំណោមមនុស្សចាស់ជរាទាំងអស់នោះ ក៏មានមនុស្សចាស់ជរាជាតិខ្មែរ ដែលត្រូវភៀសខ្លួនចេញពីមាតុភូមិរបស់ខ្លួន ហើយមករស់នៅក្នុងប្រទេសថ្មីមួយទៀត ដែលគាត់ត្រូវជួបប្រទះនូវបញ្ហាមួយចំនួន ហើយត្រូវការជំនួយជាចាំបាច់បំផុត ពីអង្គការ សមាគម ដើម្បីជួយធ្វើការទំនាក់ទំនង និងដឹកនាំគាត់ឱ្យបានទៅដល់ទីកន្លែងសំខាន់ៗ ដូចជាមន្ទីរពេទ្យមន្ទីរផ្តល់ជំនួយសង្គមកិច្ច ជួយបកប្រែភាសាជាដើម ។

អាស្រ័យហេតុនេះ បើសិនណាជានៅក្នុងសហគមន៍ជាតិខ្មែរយើង មានអង្គការ សមាគមសម្រាប់មនុស្សចាស់ជរា ហើយភារកិច្ចនៃអង្គការ សមាគមនេះ ត្រូវតែខិតខំ ប្រឹងប្រែង យកចិត្តទុកដាក់ និងប្តេជ្ញាតាំងចិត្តដោយសុទ្ធចិត្ត អនុវត្តនូវឧត្តមគតិ ក្នុងគោលបំណងជួយបីបាច់ថែរក្សាជួយដោះស្រាយបញ្ហានានា ដើម្បីជួយសម្រាលដល់សេចក្តីទុក្ខលំបាកនៃមនុស្សចាស់ជរាជាតិខ្មែរយើងឱ្យបានទទួលសេចក្តីសុខសាន្ត សុខមាលភាព និងសុវត្ថិភាពក្នុងជីវិតទាំងផ្លូវកាយទាំងផ្លូវចិត្ត រហូតដល់ថ្ងៃណាមួយដែលត្រូវលាចាកលោកនេះទៅ នោះវាជាការល្អប្រសើរប្រពៃណាស់ ។

ផ្ទុយទៅវិញ បើសិនណាជាអង្គការ សមាគមដែលជាអង្គការទទួលសុខត្រូវពីរដ្ឋ ហើយបានទទួលមូលនិធិ និងមធ្យោបាយពីរដ្ឋរួចមកហើយ ប៉ុន្តែមិនបានបំពេញភារកិច្ចបំរើសហគមន៍ឱ្យបានពេញលក្ខណៈ និងសេចក្តីទុកចិត្ត ទុកថ្លើមពីបណ្តាមនុស្សចាស់ជរាទេ អង្គការ សមាគមនោះពុំត្រូវបានបណ្តាមនុស្សចាស់ជរាទទួលស្គាល់បានឡើយ ពីព្រោះពុំបានចេញមុខមកពិភាក្សាដោះស្រាយបញ្ហាឱ្យបានត្រឹមត្រូវទៅតាមគោលការណ៍ និងគោលបំណងរបស់អង្គការ សមាគម ឃើញតែមានចាត់ចែងការងារទៅតាមពួក តាមក្រុមដែលខ្លួនគិតថា មានប្រយោជន៍សំរាប់ខ្លួនតែប៉ុណ្ណោះ ។ លក្ខណៈរបៀបនេះ ពុំអាចទុកឱ្យអង្គការ សមាគមនេះ បន្តកិច្ចការងារនេះបានទេ ត្រូវតែមានការកែសម្រួល ហើយរៀបចំជាអង្គការ សមាគមសារជាថ្មីឡើយវិញ ដើម្បីស្វែងរក និងធ្វើការជ្រើសរើសយកអ្នកគ្រប់គ្រងដឹកនាំ ដែលប្រកបដោយសុភវិនិច្ឆ័យ មានឧត្តមគតិ និងមានសេចក្តីស្មោះត្រង់ សុច្ចរិត យុត្តិធម៌ក្នុងកិច្ចការ និងភារកិច្ចរបស់ខ្លួន សមស្របទៅតាមសេចក្តីសង្ឃឹម និងសេចក្តីត្រូវការ ពឹងពុំនាក់អាស្រ័យរបស់មនុស្សចាស់ជរាជាតិខ្មែរទាំងអស់ ដែលកំពុងមានជីវិតរស់នៅក្នុងសេចក្តីទុកលំបាកសព្វថ្ងៃនេះ ៕


The Khmer Post Directory

East Coast Publication

Regional Editor : Pin Samkhon

Email : pinsamkhon@gmail.com

Writers : Mam Yin
Kim Phean
Im Loeurm
Bopea Chum

**Advertising**

**Marketing Manager:**

**Sabane Thach**

**Phone : 267-253-3947**

**Email : sabane.thach@gmail.com**

West Coast Publication

RegionalEditor : Sovannara Meach

Writers : Kim Saroeurn
Ra Neat
Sophea Rith
Mey Sampos
Chan Kosal
Sovann Rith

**Phone: (562) 313-2129**

**Email: sovannara04@yahoo.com**


## តមកពីទំព័រទី០២ បទសម្ភាសន៍ជាមួយតំណាងរាស្ត្រ...

**ចម្លើយ :** ចំពោះគណបក្សសិទ្ធិមនុស្សយើងជ្រើសយកបេសកកម្មអហឹង្សា យើងចូលចិត្តប្រើនយោបាយផ្លូវច្បាប់លើឆាកអន្តរជាតិ ។

**សំនួរ :** តើលោកអាចប្រាប់បានទេ ថាតើនៅរដ្ឋណានៃ ស.រ.អា នេះ ដែលគណបក្សសិទ្ធិមនុស្សមានប្រជាប្រិយភាពជាងគេ ?

**ចម្លើយ :** យើងឃើញនៅហ្វីឡាដែលហ្វីយ៉ានេះ មានចលនាគាំទ្រចំពោះគណបក្សសិទ្ធិមនុស្សច្រើន ។

**សំនួរ :** តើលោកអញ្ជើញមក ស.រ.អា លើកនេះ តើមានពេលវេលានឹងបំណងអ្វីខ្លះ?

**ចម្លើយ :** ខ្ញុំមកលើកនេះ ដើម្បីថ្លែងអំណរគុណដល់អ្នកដែលបានជួយដល់ចលនាគណបក្សសិទ្ធិមនុស្សក្នុងការបោះឆ្នោតសភាកន្លងមក ហើយនោះ ទី២ យើងជំរាបរាយការណ៍ជូននូវអ្វីដែលយើងនឹងត្រូវធ្វើនៅពេលខាងមុខទៀតនោះ ដើម្បីអញ្ជើញគេឱ្យចូលរួម ហើយទី៣ គឺពីថ្ងៃ ច័ន្ទ រហូតដល់ថ្ងៃ សុក្រ ទី ១២ នេះយើងមានកម្មវិធីជួបជាមួយមន្ត្រីសភា និងរដ្ឋាភិបាលអាមេរិកាំង នៅវ៉ាស៊ីនតុនឌីស៊ី រួចហើយយើងនឹងទៅជួបបងប្អូនខ្មែរយើង នៅហ្វីឡាដែលហ្វីយ៉ានៅឡូវែល ទៅកាណាដា ដូចជា ម៉ុងរ៉េអាល់ អូតាវ៉ា រួចមកទៅ វ៉ាស៊ីនតុនស្តេត ទៅមីនីសូតា រួចហើយបានទៅ កាលីហ្វ័រនីញ៉ា ។

**សំនួរ :** សូមអរគុណ !

***២- បទសម្ភាសន៍ជាមួយតំណាងរាស្ត្រខ្មែរ***



*មណ្ឌលព្រៃវែង លោក យែម បុញ្ញារិទ្ធ នឹងជាអគ្គលេខាធិការគណបក្សសិទ្ធិមនុស្ស ។*

**សំនួរ ថាច់ សុបិន :** តើលោកអញ្ជើញមក ស.រ.អា នេះ ក្នុងភារកិច្ចអ្វីដែរ ?

**(តទៅទំព័រទី១២)**

# នួន ជា ថា យួនជាអ្នកបំបែកបំបាក់ និងផ្តួលរំលំក្រុមខ្លួន

## ❖ ការស្រាវជ្រាវរបស់អ្នកកាសែត និងការអះអាងរបស់ ឌុច ដូចគ្នានឹងសម្តី នួន ជា កាលពី ៨ ឆ្នាំមុនៈ

**Long Beach, ខ្មែរប៉ុស្តិ៍ : ទិត្យ សុវណ្ណារិទ្ធិ**

●●●អតីតអនុលេខាបក្សកុម្មុយនិស្តកម្ពុជា ហៅថា បងធំទី2 គឺ នួន ជា បានផ្តល់កិច្ចសម្ភាសន៍ដ៏កម្រមួយឱ្យដល់លោក មាជ សុវណ្ណារ៉ា អតីតអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរក្រហម និងជាអតីតអ្នកយកព័ត៌មានរបស់វិទ្យុអាស៊ីសេរី កាលពីឆ្នាំ 2001 ដែលមានរយៈពេល8ឆ្នាំមកហើយ នួន ជា និយាយថា ថ្នាក់ដឹកនាំយួនមាន ហូ ជីមិញ និង ឡេ យន់ បានខឹងសម្បារចំពោះ ប៉ុល ពត និងខ្លួនគាត់ (នួន ជា) ដែលបានបំបែកខ្លួនចេញពីបក្សកុម្មុយនិស្តសហព័ន្ធឥណ្ឌូចិន មកបង្កើតបក្សកុម្មុយនិស្តកម្ពុជាខ្លួនឯង ដោយមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសវៀតណាម ដែលគិតថា ខ្មែរ និងឡាវ ជាប្រទេសចំណុះដែលមានបក្សតែមួយកងទ័ពតែមួយ និងរដ្ឋាភិបាលតែមួយ ។ បញ្ហានេះហើយធ្វើឱ្យមេដឹកនាំយួនរិះរកល្បិចកលបំបែកបំបាក់ និងផ្តួលរំលំក្រុមមនុស្សនៅក្នុងបក្សកុម្មុយនិស្តកម្ពុជា និងរបបខ្មែរក្រហម ។


នួន ជា និង មាជ សុវណ្ណារ៉ា អតីតអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី ថតនៅផ្សារព្រហ្មកាលពីឆ្នាំ២០០១

នួន ជា អះអាងថា ពួកចារកិច្ចយួនបានចូលមកបង្កប់ និងអូសទាញមេដឹកនាំខ្មែរក្រហមមួយចំនួននៅភូមិភាគបូព៌ាបំណងបំបែកបំបាក់កម្លាំង ធ្វើឱ្យកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមមានការមិនទុកចិត្តគ្នា រហូតដល់បញ្ហាឱ្យមានការកាប់សម្លាប់រង្គាលនៅថ្នាក់កណ្តាល និងថ្នាក់ក្រោម ដោយថ្នាក់លើពិបាកនឹងក្តាប់ពីសភាពការណ៍ដែលបានកើតមាននៅក្នុងរបបដឹកនាំរបស់ខ្លួន ។

នួន ជា និយាយថា ពួកខ្មាំងបង្កប់បានបង្កការរាំងស្ទះដល់វិស័យអភិវឌ្ឍន៍ផ្នែកកសិកម្ម និងឧស្សាហកម្ម ដោយរូបលោកលើកឡើងថា ផលស្រូវដែលបានពីការបង្កបង្កើនផលត្រូវបានគេដឹកយកទៅចាក់ចោលនៅក្នុងបឹងទន្លេសាប និងទឹកសមុទ្រ ។ រោងចក្រផលិតកសិផលនានាក៏ត្រូវបានគេបំផ្លាញដោយយកវត្ថុរឹង ដូចជា ដែក ដែកគោលទម្លាក់ចូលក្នុងម៉ាស៊ីន ធ្វើឱ្យគាំងរាំងស្ទះដល់ការផលិត ។ ដោយ នួន ជា បានដាក់ការចោទប្រកាន់ថា ពួកយួនជាអ្នកបំផ្លាញដើម្បីផ្តួលរំលំរបបខ្មែរក្រហម ។

នួន ជា បានប្រាប់ថា ប្រទេសយួនមានផែនការប្រើប្រាស់ទ័ពដើម្បីវាយរំលំរបបខ្មែរក្រហម ។ ដូច្នេះហើយបានជាយើងខំកសាងកម្លាំងសេដ្ឋកិច្ចក្នុងរយៈពេលខ្លីដោយខំធ្វើស្រែក្នុងមួយឆ្នាំ3ដង ដើម្បីរក្សាស្បៀងទុកទប់ទល់ធ្វើសឹកសង្គ្រាមជាមួយពួកយួនក្នុងការឈ្លានពាន ។ ប៉ុន្តែទីបំផុតរបបកម្ពុជាប្រជាធិបតេយ្យមួយនេះត្រូវបរាជ័យ ព្រោះតែមានអ្នកដឹកនាំមួយចំនួនជាមួយកម្លាំងមួយភាគធំនៅភូមិភាគបូព៌ាបានចុះចូលជាមួយពួកយួនក្នុងការតបត វាយបកក្នុងជម្លោះប្រដាប់អាវុធរវាងកងទ័ពយួន និងខ្មែរក្រហម បានកើតមានបញ្ហាដ៏ធ្ងន់ធ្ងរនាចុងឆ្នាំ 1977 និងដើមឆ្នាំ 1978 ដោយការប៉ះទង្គិចដោយអាវុធបានផ្តើមឡើងដំបូងនៅតាមព្រំដែនដែលកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាមបើកការវាយលុកគ្នាទៅវិញទៅមក ។

អតីតអ្នកកាសែតរបស់ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា ដែលបានបំភ្លឺក្នុងតុលាការឧក្រិដ្ឋកម្មខ្មែរក្រហមអំពីជម្លោះប្រដាប់អាវុធរវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម លោក Nayan Chanda បានអះអាងថា កងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាមមានទំនាក់ទំនងសហការគ្នាយ៉ាងខ្លាំងនៅក្រោយរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ក្នុងឆ្នាំ 1970 ។ វៀតណាមក៏បានចូលរួមជួយខ្មែរក្រហម ដើម្បីផ្តួលរំលំរបប លន់ នល់ នៅឆ្នាំ 1975 ។ ក៏ប៉ុន្តែទំនាក់ទំនងល្អរវាងវៀតណាម និងខ្មែរក្រហមបានចាប់ផ្តើមប្រេះស្រាំនៅពេលខ្មែរក្រហមឡើងកាន់កាប់អំណាចនាថ្ងៃទី 17 មេសា ឆ្នាំ 1975 ។

លោក Nayan Chanda ដែលសព្វថ្ងៃជាបណ្ឌិតការនៅមជ្ឈមណ្ឌល Yale ក្នុងសហរដ្ឋអាមេរិក **តទៅលេខក្រោយ**

NEW GOLDEN PALACE RESTAURANT
801-21 Washington Ave.
Phone: 215-627-2822

Open Daily from 10am-10pm
Dim Sum Every Day from 10am - 3pm

**Authentic Chinese & Vietnamese Cuisine**
**Very Delicious and Nutritious**

-ហាងយើងមានម្ហូបចិន នឹងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ
**ពិសេសនៅពេលរាត្រី :** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)
**ពិសេសដោយម្ចាស់ហាងៈ** មានចុះតម្លៃ **10%** លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ

**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)
**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement



Manager Special :
-10% OFF
LUNCH & DINNER
Present This Coupon

ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) **(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.

**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជាៈ**
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្តាំង ឆារសាច់គោ
- មីកន្តាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជាៈ**
- នំបញ្ចុកទឹកត្រីពិសេស
- នំបុ័ងបាតេ ឬសាច់គោអាំង
- ខគោ នំបុ័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ




# ក្តីស្នេហ៍គ្មានទីបញ្ចប់

**ដោយ : គីម ភឿន** ***(តពីលេខមុន)***

ហើយទៅចតចាំខ្ញុំនៅមុខទីចាត់ការវិទ្យាល័យ ។ នាយពលបាលឯកធ្វើតាមបញ្ជា រួចហើយបែរមកសួរបញ្ជាក់ចៅហ្វាយម្តងទៀត : ‘ ឱ្យខ្ញុំទៅតាមការពារទេទានប្រោស?’ ។ ចៅហ្វាយដ៏សុភាព និងមិនចេះវាយឫករបស់ខ្លួន សម្លឹងមុខគេញញឹម : ‘មិនបាច់ទេ! អរគុណ’ ។ រួចគាត់ក៏ដើរចូលទៅក្នុងទីចាត់ការសាលាបាត់ទៅ នៅក្រោមការភ្ញាក់ផ្អើល និងងឿងឆ្ងល់របស់បុគ្គលិកសិក្សាទាំងអស់នៅទីនេះ ។ លោកអនុសេនីយ៍ឯកលើកដៃសំពះគ្រប់គ្នារួចហើយ ទើបឧទ្ទិសនាមខ្លួនឱ្យគេស្គាល់ : ‘ខ្ញុំបាទអនុសេនីយ៍ឯក វិរះ សុំអនុញ្ញាតឱ្យបានចូល គួរសមនឹងលោកចាង-ហ្វាងវិទ្យាល័យបាទ!’ ។ ក្នុងចំណោមបុគ្គលិកទាំងអស់កំពុងក្រោកឈរទទួល មានបុរសម្នាក់ឆ្លើយយ៉ាងរួសរាន់ : ‘លោកនាយកកំពុងនៅអានឯកសារ ក្នុងការិយាល័យរបស់លោក ចាំខ្ញុំទៅជំរាបគាត់ជូន ’ ។ មួយសន្ទុះក្រោយមកលោកចាងហ្វាងដើរចេញមកដោយងឿងឆ្ងល់ លើកដៃសំពះតបនឹងភ្ញៀវផង សួរដោយរួសរាន់ទៅកាន់ភ្ញៀវផង : ‘ ខ្ញុំជាចាងហ្វាងសាលានេះ តើលោកមានការអី ខ្ញុំអាចធ្វើជូនបានទេ? ’ ។ កម្លោះ វិរះ តប : ‘ ខ្ញុំបាទជាមិត្តរបស់អ្នកគ្រូកល្យាណបុប្ផា ពេលបានត្រឡប់មកពីការសិក្សានៅប្រទេសវៀតណាមខាងត្បូងវិញ ទើបបានមកមួយចំនួននេះ ខ្ញុំបានយកមកផ្ញើលោកចាងហ្វាង និងបុគ្គលិកសិក្សាទាំងអស់នៅទីនេះអានឱ្យបានជ្រាបពីស្ថានការណ៍ស្រុកយើងសព្វថ្ងៃ ព្រោះខ្ញុំដឹងថា កាសែតមិនងាយបានយកមកលក់ដល់ស្រុកនេះទេ ទោះបីនៅឆ្ងាយពីក្រុងភ្នំពេញ មិនដល់



គួរសមនឹងលោកចាងហ្វាងដែលជាចៅហ្វាយនាយរបស់អ្នកគ្រូ ។ ជានាយទាហានម្នាក់ ខ្ញុំគ្មានអ្វីជូនលោកចាងហ្វាងទេ មានតែសារព័ត៌មាន ១០០គីឡូម៉ែត្រក៏ដោយ!។ លោកចាងហ្វាងព្រមជាមួយគ្នានឹងពាក្យឆ្លើយថា " ប្រាកដហើយទាន " ក៏លូកដៃទៅទទួលយកសារព័ត៌មានមួយចំនួនធំពីដៃលោកអនុសេនីយ៍ឯក ។ គាត់ចោលភ្នែកសម្លឹងទៅលើគំនរសារព័ត៌មានទាំងអស់នោះឃើញសារព័ត៌មាននគរធំនៅលើគេ ។ គាត់ក៏និយាយទៅកាន់ភ្ញៀវដោយរីករាយ : ‘ ជិតដល់ម៉ោងចេញរៀនដែរហើយ ខ្ញុំសុំជូនលោកអនុ-សេនីយ៍ឯកទៅជួបអ្នកគ្រូឯថ្នាក់គាត់ ហើយឱ្យគាត់នាំលោកទៅជួបជុំគ្នាឯគេហឋានរបស់គាត់តែម្តង ’ ។ មួយសន្ទុះក្រោយមករថយន្តស៊ីវិលក៏បរពីសាលាចេញទៅនាំទាំងអ្នកគ្រូ កល្យានទៅជាមួយបាត់ទៅដែរ ។

❖❖❖❖❖

ពេលឡានហ្ស៊ីប $A_2$ (អាដឺ) ចតនៅមុខផ្ទះរួចហើយអ្នកគ្រូកល្យាណបុប្ផា ចុះមុនគេ ដោយស្ពាយសំពាធឯកសារសិក្សាជាមួយផង ហើយអញ្ជើញកម្លោះអនុសេនីយ៍ឯកឱ្យដើរតាមខ្លួនឡើងទៅលើផ្ទះ ។ សំឡេងដ៏ស្រួយខ្ចីឱទានឡើង :

- លោកយាយអើយ លោកយាយ ! មានភ្ញៀវមកលេង ។ លោកយាយចំណាស់ប្រហែល ៧០ឆ្នាំ នៅតែមានទឹកមុខស្រស់ស្រាយ ក្មេងជាងអាយុ ស ស្រអែម ក្នុងដំណើរមួយៗ ចូលមកបន្ទប់ទទួលភ្ញៀវ ។ ចៅស្រីគាត់បែរមករកកម្លោះ វិរះ ដោយញញឹម :

- នេះលោកយាយណា វិរះ !

- ជំរាបសួរលោកយាយធ្លាប់តែឮ កល្យាណបុប្ផា និយាយពីលោកយាយ ពីការសប្បាយរីក-រាយរស់នៅក្បែរលោកយាយ ខ្ញុំពិតជាចង់ឃើញចង់ស្គាល់លោកយាយខ្លាំងណាស់ ។ យាយចាស់ស្លូតបូត បានលើកដៃសំពះតប វិរះ ដោយញញឹម :

- យាយក៏ធ្លាប់ឮនាងនិយាយពីចៅឱ្យយាយស្តាប់ដែរ ... ល្អណាស់ចៅ ដែលបានរាប់អានគ្នាយ៉ាងស្មោះស្ម័គ្រយ៉ាងនេះ ។ ក្រោយពីអង្គុយនិយាយគ្នា សំណេះសំណាលពីនេះ ពីនោះបន្តិចមកលោកយាយក៏លាអ្នកទាំងពីរទៅធ្វើម្ហូបបង្អើយសម្រាប់ថ្ងៃត្រង់ ។

នៅតែពីរនាក់ក្នុងបន្ទប់ទទួលភ្ញៀវ អ្នកគ្រូបែរមក វិរះ បន្ទោសដោយក្តីស្រឡាញ់ :

- ម៉េចក៏មកមិនឱ្យដំណឹងមុន ?

- បងលៃឱ្យតែមានពេលនឹងមកភ្លាម មិនមានពេលនឹងជូនដំណឹងបានទេ ។ សមរភូមិកំពុងត្រូវការបង គ្មានពេលទំនេរបានជួបអូនងាយៗទេ ។ មានពេលទំនេរបានមកជួបអូនថ្ងៃនេះ ជាការប្រសើរណាស់ទៅហើយ ពេលវេលារបស់ទាហានពេលស្រុកមានសង្គ្រាម ពិតជាមានតិចណាស់ ។ ចាប់ពីថ្ងៃស្អែកទៅជីវិត និងពេលវេលារបស់បង គឺជាតិនឹងមេកើយ ចៅហ្វាយនាយជាអ្នកកំណត់... បរិយាកាសស្ងៀមស្ងាត់ បានក្រាលគ្របមកលើបន្ទប់ទទួលភ្ញៀវ អ្នកទាំងពីរនៅស្ងៀមទ្រឹង រកនឹកនិយាយអ្វីលែងចេញ ។ យូរណាស់ ទើប វិរះ បន្លឺវាចាជាថ្មី :

-អូនបុប្ផា ! បងសែនបារម្ភខ្លាំងណាស់ ពេលមិនឃើញអូនទៅទទួលបង ពេលបងចុះពីយន្តហោះ ។ ម្យ៉ាងទៀតន័យក្នុងសំបុត្រអូនធ្វើឱ្យបងយល់មិនច្បាស់ថា យើងនឹងមានអ្វីៗមិនល្អនៅចាំពីមុខយើង... មានរឿងអ្វីទៅអូន ? បងសែនទុក្ខសោកខ្លាំងណាស់ ។

នាងឱនមុខចុះ ហាក់ដូចក្តីទុក្ខសោក បានយាយីនាងជាអាលដីទៅហើយ ។ នាងងើបឡើងសម្លឹងមុខប្រុសសំឡាញ់ :

- បង ! អូនមិនចង់ឱ្យបងដឹងនូវអ្វីៗដែលបានធ្វើឱ្យអូនបៀមទុក្ខតែម្នាក់ឯង ។ តែមិនអាចលាក់ទុកបានទៀតទេ ពេលដែលកាលៈទេសៈតម្រូវឱ្យអូនទៅទទួលបងនៅព្រលានយន្តហោះនោះ ។ អូនត្រូវប៉ាម៉ាក់ចង់ឱ្យមានប្តី ។ បុរសនោះជាកូនកម្លោះរបស់មេទ័ពម្នាក់ ជាមិត្តភ័ក្តិរបស់លោកប៉ា ។ គេបានបញ្ចប់ការសិក្សានៅប្រទេសបារាំង ហើយបានទទួលសញ្ញាប័ត្រវិស្វករកសិកម្ម ជំនាញខាងដំណាំប្រទេសក្តៅ ។ ហេតុនេះហើយទើបអូនមិនហ៊ានទៅទទួលបងខ្លាចធ្វើឱ្យប៉ាម៉ាក់ប្រកាន់ខឹងកាន់តែខ្លាំងឡើង ពេលប៉ាម៉ាក់ បានជ្រាបពីរឿងនេះ ។

- ចុះអូនគិតយ៉ាងណាចំពោះរឿងយើង ?

- គ្មានគិតអ្វីក្រៅពីរង់ចាំបងទេ ។ ប៉ាម៉ាក់មិនបង្ខំឱ្យតែឈ្មោះនោះទេ ហើយអូនក៏មិនចចេសតាមទំនើងចិត្តដែរ គ្រាន់តែបង្ហាញប៉ាម៉ាក់ ឱ្យជ្រាបថា ( **សូមរង់ចាំអានភាគបន្ត** )

*Washington Wellness Care*

●បើលោកអ្នកមានគ្រោះថ្នាក់រថយន្ត. មានរបួសនៅកន្លែងធ្វើការ ឬក៏រអិល ហើយដួលរហូតដល់មានរបួសតែពុំដឹងនរណាជា អ្នកទទួលខុសត្រូវ ?




**●យើងអាចជួយលោកអ្នកបាន**

●មជ្ឈមណ្ឌល "វ៉ាស៊ីនតុនវែលណេសឃែ" មានបទពិសោធន៍ក្នុងរឿងរបួសក្នុងគ្រោះថ្នាក់រថយន្ត មានរបួសនៅកន្លែងធ្វើការនឹងរអិលដួលបណ្តាលឱ្យរបួស

●យើងណែនាំទៅមេធាវីដែលអាចការពារសិទ្ធិលោកអ្នកបាននៅពេលមានគ្រោះថ្នាក់

●អាចផ្តល់ផែនការណ៍ជួយចេញសោហ៊ុយចំពោះបុគ្គលដែលគ្មានប័ណ្ណធានារ៉ាប់រង

●សូមទូរស័ព្ទមក "វ៉ាស៊ិនតុនវែលខែល" ភ្លាម ដើម្បីឱ្យដឹងថា តើយើងអាចជួយលោកអ្នកដោយវិធីណា

**រីតា និយាយភាសាខ្មែរ លេខទូរស័ព្ទ : 215-380-1350**

500 Washington Ave., 1st Fl. Philadelphia, Pa 19147 Phone: 215-551-6838

# អតីតយុទ្ធជនស្ម័គ្រចិត្តត្រូវបានទទួលស្គាល់


ឧត្តមសេនីយ៍ត្រី ម៉ម យីន

•••អតីតយុទ្ធជនខ្មែរ ទើបនឹងបានទទួលស្គាល់នូវគុណបំណាច់ក្នុងរយៈពេលដែលខ្លួនបានបំរើក្នុងកងទ័ព តើអ្នកទាំងនោះ បានធ្វើអ្វីខ្លះសម្រាប់ប្រវត្តិសាស្ត្រនៅកម្ពុជា **បូពា ជុំ** បានស្តាប់យុទ្ធជនម្នាក់ម្តងៗ ហើយរាយការណ៍ជូនសណ្តាប់ :

## Cambodian Volunteer Reserves to be Recognized :

**Mam Yin**

Mam Yin was born in Kom Pong Cham, Cambodia. He is the oldest son of his family. Mam has various teaching experiences. In 1958, he also taught at the Institute of Technology in Quebec, Canada. From1959-1970, he taught at the Technical University of Cambodia. In 1970, Mam joined the National Khmer Armed Forces. There he became a captain, commanding a battalion.

In 1971-1975, Mam was sent to Phnom Penh where he was promoted to Lieutenant Colonel in the Central Direction of Engineering Corps. Mam remembers the fall of Phnom Penh very well. He was at work when the Khmer Rouge told him that he must gather his belongings and leave the city. With his 11 relatives and family members, he was sent to Battambang province and forced to take on farm labor. Under the many cruel conditions, only Mam and his sons survived.

Mam still cannot unders and why or how the Khmer Rouge were able to kill their own people. "When leaders, like Pol Pot, come in to power, they should protect, serve, and support their people and country. A leader is supposed to be knowledgeable and bring their people prosperity and safety. Why did they use their power to bring suffering, pain, and death? Why did they kill? What were they thinking?"

Despite his trauma, Mam has had a successful life. From 1979-1993, he served under General Son San and General SakSout Sokhorn, working for the Khmer People Liberation National Front (K.P.L.N.F) and the Khmer People Liberation National Armed Forces (K.P.L.N.A.F.). At that time, he was promoted again and worked in logistics. Lieutenant Colonel Mam helped and provided support in the Cambodian 1993 election process. Mam immigrated to the United States in 1993 and has been an active member of the human rights organizations. He is very involved in his community. Mam is also a writer for the Khmer Post II, as a political analyst. At times, he contributes poetry for the newspaper. He is very happy to continue to be able to serve both Cambodia and the United States.

# Asian American Heritage Month

**Nary Kith** រដ្ឋ ផែនស៊ីវេនា




លោកចៅហ្វាយ អិដ រ៉ែនដល់ បានធ្វើសេចក្តីប្រកាសថា ខែឧសភា គឺជាខែនៃសម្បត្តិវប្បធម៌សម្បូរនៃជនជាតិអាស៊ី ប៉ាស៊ីហ្វិក អាមេរិកាំង ។

នារី គិត បានពិចារណាថា តើនៅឆ្នាំ ២០០៩ នេះ មានជនជាតិអាស៊ី ប៉ាស៊ីហ្វិក អាមេរិកាំង ប៉ុន្មាននាក់ហើយ ដែលបានខ្វល់ខ្វាយពីខែដែលឧទ្ទិសសំរាប់ពួកគេនោះ ។ តើទៅអនាគតទៅបុណ្យខួបនៃកេរ្តិ៍មរតកវប្បធម៌អាស៊ី នឹងក្លាយជាអ្វីទៅអនាគត ?

នារី គិត ជាយុវនារីខ្មែរ-អាមេរិកាំង នៅមានសេចក្តីសង្ឃឹមច្រើន ។

In 2009, Governor Ed Rendell declared May as Asian Pacific American Heritage month to celebrate the richness of the diversity of the Asian American culture. How many people of the Asian Pacific American culture were aware that there was a month designated for them? And what will happen in future Asian Pacific American Heritage months ?

My hope is that we will at minimum use the month of May to educate other cultures about the Asian Pacific American heritage; about our traditions and our values while also teaching people of our own culture about the importance of celebrating and preserving our tradition s and values. It is unfortunate that too many young people of the Asian Pacific American culture are ignorant to their own culture by no fault of their own but by the mere exposure to the dominant culture's traditions and values. This exposure causes great confusion, which causes the younger generation to question their ideologies and experience conflict with the older generation.



My hope is that because the dominant culture has recognized the importance of the Asian Pacific American culture, people of the Asian Pacific American culture will too.

ART OF WELLNESS CENTER



Art of Wellness
"Integrating Holistic Healthcare for the Mind, Body, and Spirit."
(215)305-2238
www.artofwellnesscenter.com



មន្ទីរសុខភាព"Art of Wellness"ទទួលព្យាបាលបញ្ហាផ្លូវចិត្តនឹងកាយធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នក របៀបបច្ចេកទេស និងបច្ចេកវិទ្យាបច្ចិមប្រទេស ។

ទទួលព្យាបាលបានគ្រប់វ័យ

| របៀបព្យាបាល | TREATMENT TYPE |
|---|---|
| ប្រើម្ជុលឥតថ្នាំ | Acupuncture |
| ចាប់សរសៃ | Acupressure |
| ចិត្តវិទ្យា | Psychotherapy |
| យោគ/ ភាវនា | Yoga / Meditation |

ដោយបណ្ឌិតនិងអ្នកជំនាញការមានបទពិសោធន៍ច្រើនឆ្នាំ នៅប្រទេសចិន និងនៅសហរដ្ឋអាមេរិក ៕

សូមអញ្ជើញទូរស័ព្ទ ឬមកមន្ទីរពេទ្យសុខភាពយើងខ្ញុំ ដើម្បីពិគ្រោះវិធីព្យាបាល

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម:

| | | | |
|---|---|---|---|
| ធ្លាក់ទឹកចិត្ត | DEPRESSION | ឈឺខ្លួនប្រាណគ្រប់កន្លែង | PAIN MANAGEMENT |
| ការថប់អារម្មណ៍ | ANXIETY | មានវិបត្តិក្នុងគ្រួសារ | FAMILY ISSUES |
| ភាពតានតឹង | STRESS | ការញៀន និងអ្វីមួយ | ADDICTION ISSUES |
| មានកំហឹងច្រើន | ANGER MANAGEMENT | សុខភាពស្ត្រី | WOMEN'S HEALTH |

ART OF WELLNESS CENTER
647 BAINBRIDGE SREET
PHILADELPHIA, PA 19147
215-305-2238
ភាសាខ្មែរទាក់ទង ប៊ុន គីត : 267-242-8526

តមកពីទំព័រទី០១

# ចលនាប្រជាធិបតេយ្យ...

### សន្ទរកថា លោក សម រង្ស៊ី

ខ្ញុំសូមអរគុណដល់បងប្អូនទាំងអស់គ្នា ដែលបានផ្តល់កិត្តិយសឱ្យខ្ញុំ និងឯកឧត្តម កឹម សុខា មានឱកាសជួបជុំនឹងបងប្អូននៅទីនេះ យើងនៅមានពេលថ្ងៃ



លោក សម រង្ស៊ី

ស្អែកនិយាយលំអិតអំពីបញ្ហារបស់ ប្រទេសជាតិយើង ដូចនេះ ខ្ញុំគ្រាន់តែសង្ខេបនៅយប់នេះថា ហេតុអ្វីបានជាយើងខិតខំប្រមូលកម្លាំងស្នេហាជាតិ ឱ្យបានធំតែមួយ ន័យដើម្បីសម្រេចគោលដៅរបស់យើងឱ្យបានក្នុងឱកាសដ៏ខ្លីខាងមុខ គឺនៅបីទៅបួនឆ្នាំខាងមុខនេះ ។ យើងទាំងអស់គ្នាដឹងថា ទាល់តែកម្លាំងប្រជាធិបតេយ្យយើងរួបរួមគ្នា ទើបយើងឈ្នះពួកអតីតកុម្មុយនិស្តដែលគេប្តូរឈ្មោះ ប៉ុន្តែសារជាតិនៅតែកុម្មុយនិស្ត មិនតែប៉ុណ្ណោះសោត ពួកគេបំរើយួនឈ្លានពាន ដែលកំពុងតែលេបប្រទេសកម្ពុជា បន្ទាប់ពីគេបានលេបកម្ពុជាក្រោមរួចបាត់ទៅហើយនោះ ។

ខ្ញុំមានបទពិសោធន៍មួយ ដែលខ្ញុំបានចូលរួមក្នុងចលនាដ៏ធំមួយ គឺហ្វ៊ុនស៊ិនប៉ិច ពេលនោះជាកម្លាំងធំជាងគេ ដែលបានទទួលជ័យជំនះលើកុម្មុយនិស្ត ពេលនោះបើយើងវិភាគទៅមានតែកម្លាំងជាតិនៃហ្វ៊ុនស៊ិនប៉ិចទេ ទើបឈ្នះ អញ្ចឹងហើយខ្ញុំក៏ចូលក្នុងចលនាហ្វ៊ុនស៊ិនប៉ិច ហើយបានឈ្នះមែន រឿងវាវែងឆ្ងាយ ។ យើងអាចឈ្នះបើយើងរួបរួមគ្នាដូចឆ្នាំ ១៩៩៣ បើមានកម្លាំងតែ១ទល់នឹង១ បើអ្នកស្នេហាជាតិប្រឆាំងទល់នឹងអ្នកបំរើបរទេស អ្នកប្រជាធិបតេយ្យទល់នឹងអ្នកកុម្មុយនិស្តផ្តាច់ការ ដូច្នេះបើ១ទល់នឹងមួយ គឺមិនឈ្នះកម្លាំងអ្នកស្នេហាជាតិទេ ដូច្នេះគោលដៅយើង គឺរៀបចំកម្លាំងធំមួយដូចឆ្នាំ ១៩៩៣ ដើម្បីទទួលជ័យជំនះឱ្យទាល់តែបាននៅឆ្នាំ ២០១៣ ។ គណបក្ស ហ្វ៊ុនស៊ិនប៉ិច ពេលដែលមានខ្ញុំជាសមាជិក មេដឹកនាំគេបោះបង់ឧត្តមគតិ គេទម្លាក់ចោល ខ្ញុំខំស៊ុះទៅទ្រ ហើយលើកទូលឧត្តមគតិដើមយើងឱ្យបាន ។ ឧត្តមគតិដើមរបស់យើងនោះ គឺ**ទី១** ប្រឆាំងនឹងយួនឈ្លានពាន **ទី២** ប្រឆាំងកុម្មុយនិស្តផ្តាច់ការ **ទី៣** ប្រឆាំងអំពើពុករលួយ **ទី៤** ការពារផ្តល់យុត្តិធម៌ជូនប្រជារាស្ត្រខ្មែរ តែយើងកត់សំគាល់ឃើញថា អ្នកដឹកនាំដែលបានឈ្នះឆ្នាំ ១៩៩៣ បានផ្លាស់ប្តូរទាំងស្រុង គឺទៅចូលដៃជាមួយពួកអាយ៉ងយួន ទៅចូលដៃធ្វើរដ្ឋាភិបាលរណបគេ ទៅចូលដៃជាមួយជនប្រព្រឹត្តអំពើពុករលួយ ទៅចូលដៃជាមួយពួកខិលខូចយកដីរបស់ប្រជាពលរដ្ឋ ធ្វើបាបជនក្រីក្រ បើយើងចេះរក្សាកម្លាំងរួបរួមស្នេហាជាតិបាន យើងនឹងឈ្នះ ខ្ញុំជឿថា ចលនាប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរនៅប្រទេសកម្ពុជានឹងរីកចំរើនឡើងទាំងនៅកម្ពុជា



លោក សម រង្ស៊ី និង លោក កឹម សុខា កំពុងជួបសំណេះសំណាល់ជាមួយបងប្អូនខ្មែរយើងនៅហ្វីឡា

ទាំងនៅឯនាយសមុទ្រ ។ ដូចនេះ ខ្ញុំជឿថា បងប្អូននឹងឯកភាពជាមួយខ្ញុំ លើមូលដ្ឋាននៃគំនិតដែលខ្ញុំបានរំលឹកអម្បាញមិញថា " យើងបានឈ្នះពួកកុម្មុយនិស្តម្តងហើយ យើងនឹងបានឈ្នះម្តងទៀត" កុំគេបំបាក់ស្មារតីយើង ដូចជាថា យើងមិនងាយឈ្នះទេ កុម្មុយ-និស្តខ្លាំងណាស់ ហ៊ុន សែន ខ្លាំងណាស់ ដរាបណាយើងនៅរក្សាគំនិតដើមរបស់យើងឱ្យបានរឹងប៉ឹង យើងនឹងបានឈ្នះម្តងទៀតជាមិនខាន ។

ខ្ញុំសូមអរគុណបងប្អូនជាថ្មីម្តងទៀត ហើយសង្ឃឹមថានឹងជួបបងប្អូននៅលើទឹកដីកម្ពុជា តស៊ូធ្វើឱ្យសម្រេចជោគជ័យ " ចលនាប្រជាធិតេយ្យដើម្បីផ្លាស់ប្តូរ " ។



សុបិន ថាច់ និង យី ដារ៉ាវ៉ាន់ ពិធីករ

### សន្ទរកថា លោក កឹម សុខា

សូមជំរាបសួរអស់លោក លោកស្រី ជនរួមជាតិជាទីគោរព ជាទីស្រឡាញ់ នេះជាឱកាសដ៏នក្ខត្តឫក្ស ដែលបងប្អូននៅទីនេះ បានជួបខ្ញុំកាលពី ២ឆ្នាំមុន បាន



លោក កឹម សុខា

ធ្វើសំណូមពរឱ្យមានថ្ងៃនេះ ដែលសំខាន់ គឺបងប្អូនចង់ឃើញការរួបរួមគ្នា រវាងអ្នកប្រជាធិបតេយ្យ និងអ្នកប្រជាធិបតេយ្យ អស់លោកអ្នកបានផ្តួចផ្តើមគំនិតឱ្យខ្ញុំបង្កើតគណបក្សសិទ្ធិមនុស្ស ឥឡូវគណបក្សនេះបានកើតឡើងហើយ ដូច្នេះទិសដៅរបស់គណបក្សសិទ្ធិមនុស្ស គឺប្រឆាំងនឹងការឈ្លានពានរបស់បរទេស ទិសដៅ គឺប្រឆាំងនឹងអំពើផ្តាច់ការរបស់កុម្មុយនិស្តផ្តាច់ការ ទិសដៅរបស់គណបក្សសិទ្ធិមនុស្ស គឺជួយស្រោចស្រង់ប្រជាពលរដ្ឋយើងដែលរងទុក្ខវេទនាឱ្យមានជីវិតភាពល្អប្រសើរ ។

បងប្អូនបានស្តាប់ប្រសាសន៍របស់ឯកឧត្តម សម រង្ស៊ី ហើយ យើងឃើញថា យើងឥតមានអ្វីខុសគ្នាសោះ ហេតុអ្វីយើងមិនអាចរួបរួមគ្នាបាន ? ថ្ងៃនេះសេចក្តីប្រាថ្នារបស់យើង គឺបានទទួលហើយ ។ ក្នុងនាមខ្ញុំជាប្រធានគណបក្សសិទ្ធិមនុស្ស សូមថ្លែងអំណរគុណចំពោះលោក លោកស្រី ដែលបានខំចំណាយសតិស្មារតីគិតគូរបញ្ហាប្រទេសជាតិ ដោយផ្តល់ទាំងគំនិត ទាំងមធ្យោបាយ ជាពិសេស ថវិកាពេលវេលាជួយដល់គណបក្សសិទ្ធិមនុស្ស ឱ្យកើតឡើងបានរហូតដល់សព្វថ្ងៃនេះ ដូច្នេះ សូមអរគុណដល់បងប្អូននៅហ្វីឡានេះ បានជួយខ្លាំងជាងគេទាំងអស់ ។

ដោយសារថ្ងៃស្អែកយើងខ្ញុំនឹងជម្រាបជូនឱ្យបានលំអិតទៅទៀត ខ្ញុំជម្រាបជូនដោយសង្ខេបពេលនេះថា ទិសដៅទៅមុខទៀតរបស់គណបក្សសិទ្ធិមនុស្ស គឺរួមឱ្យបានជាដាច់ខាតជាមួយអ្នកប្រជាធិបតេយ្យ ជាពិសេស ជាមួយគណបក្ស សម រង្ស៊ី ហើយលោកអ្នកបានជ្រាបហើយ ការរួបរួមនេះ គឺដើម្បីការផ្លាស់ប្តូរ ប្តូរពីអ្នកដឹកនាំរណបបរទេស ទៅជាអ្នកដឹកនាំឯករាជ្យពិតប្រាកដ ប្តូរពីអ្នកដឹកនាំផ្តាច់ការនិយម ទៅជាអ្នកដឹកនាំប្រជាធិបតេយ្យពិតប្រាកដ ប្តូរពីអ្នកដឹកនាំពុករលួយ ទៅជាអ្នកដឹកនាំស្អាតស្អំពិតប្រាកដ ដូច្នេះ នេះជាបំណងរបស់បងប្អូននៅទីនេះ ក៏ដូចជាបងប្អូននៅឯក្នុងប្រទេសដែរ ក៏ប៉ុន្តែសួរថា ហេតុអ្វីយើងប្តូរមិនបានកន្លងមក យើងមិនបានរៀបចំយុទ្ធ-សាស្ត្រអ្វីច្បាស់លាស់ យើងមិនមានកំណត់ទិសដៅច្បាស់លាស់ ដូច្នេះ បានជាពេលនេះ គណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី ចាប់ផ្តើមជជែកគ្នាពីយុទ្ធសាស្ត្រ ហើយនឹងទិសដៅនៃការរួបរួមគ្នានេះឱ្យបានច្បាស់លាស់ ដើម្បីឱ្យប្រាកដថា ការរួបរួមគ្នានេះ គឺដើម្បីជាតិ និងប្រជាពលរដ្ឋខ្មែរប្រាកដមែន ។

ជាការចាប់ផ្តើម ខ្ញុំជឿថាបងប្អូនទាំងអស់មានទាំងខ្មែរក្រៅស្រុក ខ្មែរក្នុងស្រុក រាប់ទាំងខ្មែរក្រោម ខ្មែរកណ្តាល ខ្មែរលើផងដែរ ជាខ្មែរតែមួយ ដូច្នេះហើយយើងចង់ឃើញខ្មែរតែមួយ ដែលដើម្បីជួយស្រុកខ្មែរឈរលើលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ៕

**សូមអរគុណ !**


AMERICAN LEGION POST 153
PRESENTS



FRANTIC
DJ FRIDAY AND SATURDAY
FROM 9 P.M. – 3 A.M.
MEMBERS ONLY
SMOKING PERMITTED

សូមអញ្ជើញមកកំសាន្ត ពិសារភេសជ្ជៈ រាំកំសាន្តនៅ " ហ្វ្រង់ទិក "

2514 S. 24TH ST.
PHILA., PA 19145
215-551-1950

បន្ធូរបរិយាកាសយ៉ាងត្រជាក់ចិត្ត
បន្ទាប់ពីធ្វើការងារហត់នឿយ !

- កន្លែងកំសាន្តធំទូលាយ - ស្តាប់ភ្លេងយ៉ាងពិរោះអស្ចារ្យ ឬក៏បុកប៊ីយ៉ា ក៏មានជូនកំសាន្តដែរ ។
- យើងខ្ញុំរីករាយណាស់នឹងឃើញលោក-អ្នកអញ្ជើញមក !
- ថ្ងៃសុក្រ-សៅរ៍ ពីម៉ោង៩ដល់ម៉ោង៣ព្រឹក **DJ** នឹងបណ្តែតអារម្មណ៍ លោក-អ្នកតាមតន្ត្រីសំរាំងថ្មីៗ





ចង់ជួលសាល ឬចង់បានម្ហូប
ជប់លៀង យើងធ្វើជូនបាន !

HALL RENTAL & CATERING
AVALIABLE REASONABLE PRICE

FOR ADVERTISING , CALL (267) 253-3947




ទឹកជ្រោះភ្នំគូលែន

ភ្នំគូលែន គឺជាអតីតរាជធានីដំបូងនាសម័យមហានគរ ដែលព្រះបាទជ័យវរ្ម័នទី2 បានរៀបចំពិធីទេវរាជនៅលើកំពូលភ្នំនោះ ព្រមទាំងមានការសង់ប្រាសាទមួយចំនួនទៀត ដើម្បីឧទ្ទិសថ្វាយចំពោះលទ្ធិព្រាហ្មណ៍សាសនា ។ នៅលើកំពូលភ្នំមានរុក្ខជាតិតូចធំដុះប្រជ្រៀតគ្នា សត្វបក្សាបក្សី ជប់ព្រះចម្លាក់លិង្គ និងយោនី1000ក្នុងស្ទឹងសៀមរាប ទឹកជ្រោះធ្លាក់ពីកំពូលភ្នំខ្ជូបប្រាំងខ្ជូបវស្សា និងព្រះអង្គធំចូលនិព្វានយ៉ាងធំ ។

បច្ចុប្បន្នភ្នំគូលែនក្លាយជារមណីយដ្ឋានធម្មជាតិដែលទាក់ទាញភ្ញៀវទេសចរជាតិ-អន្តរជាតិចម្រុះជាតិសាសន៍ឱ្យទៅទស្សនាកម្សាន្តនៅថ្ងៃបុណ្យផ្សេងៗយ៉ាងច្រើនកុះករ ដោយទីនោះមានសម្រស់ធម្មជាតិល្អប្រព័ន្ធគមនាគមន៍ធ្វើដំណើរក៏ល្អ ហើយនៅលើកំពូលភ្នំមានវត្តអារាម ព្រះសង្ឃពុទ្ធបរិស័ទ ពួកអាជីវករទៅប្រកបអាជីវកម្មជាហូរហែ និងមានសន្តិសុខល្អទៀតផង ។

# រមណីយដ្ឋានភ្នំគូលែនអតីតរាជធានីដំបូង សម័យមហានគរ



ព្រះអង្គធំចូលនិព្វាន

**សៀមរាប, ខ្មែរប៉ុស្តិ៍ : គីម សារឿន**

●●● រមណីយដ្ឋានភ្នំគូលែនស្ថិតនៅប្រជុំស្រុកពីរ គឺស្រុកស្វាយលើ និងស្រុកវ៉ារិន្ទ ដែលមានចម្ងាយប្រមាណ60គីឡូម៉ែត្រពីទីរួមខេត្តសៀមរាប ។ ទីកន្លែងនេះកាលពីសម័យមុនជារាជធានីចាស់ដំបូងបំផុតនាសម័យមហានគរ បន្ទាប់ពីព្រះបាទជ័យវរ្ម័នទី2រំដោះប្រទេសជាតិរួចផុតពីការឈ្លានពានរបស់កងទ័ពជ្វា ហើយបានយកសាសនាព្រហ្មញ្ញដើម្បីបង្រួបបង្រួមផ្សំផ្សារជាតិតាមរយៈលទ្ធិទេវរាជនៅកំពូលភ្នំគូលែននោះ ។

ភ្នំគូលែននេះឈ្មោះដើម មហិន្ទ្របព៌ត ក្នុងសម័យនោះព្រះអង្គបានរៀបចំកសាងប្រាសាទជាច្រើននៅលើកំពូលភ្នំ ដើម្បីឧទ្ទិសថ្វាយចំពោះ សាសនាក្នុងរជ្ជកាលព្រះអង្គគ្រងរាជ្យសម្បត្តិ-ចាប់តាំងពីឆ្នាំ 802 រហូតមកដល់ព្រះរាជាក្រោយៗទៀត ។ ទិដ្ឋភាពលើកំពូលភ្នំនេះ ក្នុងសម័យសង្គ្រាមគេសង្កេតឃើញមានមីនបង្កប់ក្នុងដីយ៉ាងច្រើន ដើម្បីប្រឆាំងនឹងជីវិតមនុស្ស ហើយតំបន់នេះគ្រប់គ្រងដោយអតីតពួកខ្មែរក្រហម មិនសូវមានមនុស្សចេញចូលឡើយ ។

ប៉ុន្តែចាប់តាំងពីពួកខ្មែរក្រហមរលំរលាយអង្គការចាត់តាំងរបស់ខ្លួនទាំងស្រុងទីនេះបានក្លាយទៅជាតំបន់ទេសចរណ៍ធម្មជាតិ មានព្រះសង្ឃពុទ្ធបរិស័ទកសាងវត្តអារាមសម្រាប់គោរពបូជា ក្រុមអ្នកស្រុកឡើងទៅប្រកបមុខរបរលក់ដូរ អ្នកទេសចរចេញចូលយ៉ាងច្រើនជារៀងរាល់ថ្ងៃ ព្រមទាំងមានការអភិវឌ្ឍប្រព័ន្ធគមនាគមន៍សម្រាប់ធ្វើដំណើរដោយថ្មើរជើងឬរថយន្តតាំងពីក្រោមរហូតដល់កំពូលភ្នំយ៉ាងងាយស្រួលបំផុត មិនដែលបង្កគ្រោះថ្នាក់អ្វីគួរឱ្យកត់សម្គាល់ដល់អ្នកទេសចរឡើយ ។

នៅពេលដែលយើងឡើងដល់ចង្កេះភ្នំ ត្រង់ចំណុចជប់ព្រះដែលមានដីរាបស្មើ មានអាស្រមតាជី យាយជី រូបពុទ្ធបដិមាករ ព្រមទាំងមានទឹកហូរចេញពីរូងថ្មត្រជាក់ស្រេបដូចទឹក អម្រឹត ខ្ជូបប្រាំង ខ្ជូបវស្សា ដែលស្ថិតនៅក្បែរដើមចំប៉ាមានមុខកាត់ 0,7 ម៉ែត្រ និងកម្ពស់15ម៉ែត្រ ទឹកជប់ព្រះនេះត្រូវបានក្រុមអ្នកទេសចរជិតឆ្ងាយ យកដៃក្បង់ទឹកសម្រាប់លុបមុខ ឬផឹកដោយសន្មត់ជាទឹកស័ក្តិសិទ្ធិអាចព្យាបាលជំងឺក្នុងខ្លួនទៀតផង ។

អ្នកខ្លះដែលមានជំនឿខ្លាំងក៏អុជធូបបួងសួងសុំទឹកនោះដាក់ដបយកមកផ្ទះសម្បែង ដើម្បីឱ្យក្រុមគ្រួសារសម្រាប់រំដោះគ្រោះលើករាសីឱ្យចៀសផុតពីគ្រោះចង្រៃផ្សេងៗ ។ នៅពេលគេបន្តដំណើរទៅមុខបន្តិចទៀតនឹងឃើញស្ទឹងមួយមានទឹកថ្លាឈ្វេងឆ្លុះដល់បាតដី ដែលមានចម្លាក់រូបលិង្គ1000 និងយោនីព្រះនាងឧមា ដើម្បីឧទ្ទិសថ្វាយចំពោះលទ្ធិព្រហ្មញ្ញ សាសនាតាមជំនឿនាសម័យនោះពាសពេញបាតស្ទឹង ដោយមានទឹកហូរមិនចេះរីងស្ងួត រូបចម្លាក់ទាំងនេះត្រូវបានក្រុមអ្នកទេសចរថតទុកជាអនុស្សាវរីយ៍ ។

ខណៈពេលធ្វើដំណើរទៅដល់បរិវេណលើកំពូលភ្នំ គេសង្កេតឃើញមានសំណង់វត្តអារាម ព្រះវិហារ កុដិព្រះសង្ឃ សម្រាប់គោរពបូជា ដែលទើបកសាងនាសម័យក្រោយៗនេះ ហើយអ្វីដែលគេចាប់អារម្មណ៍ជាងនេះទៅទៀតនោះ គឺព្រះអង្គ ដែលកសាងឡើងក្នុងសតវត្សទី16 នៅលើដុំថ្មមួយផ្ទាំង គឺព្រះពុទ្ធចូលនិព្វាន មានកម្ពស់7,5ម៉ែត្រ និងបណ្តោយ 8ម៉ែត្រ ដែលអ្នកផងតែងតែទៅគោរពបូជា ធ្វើការបន់ស្រន់ដោយម្នាក់ៗជឿថា មានបារមីខ្លាំងក្លា នៅក្បែរព្រះអង្គធំមានដើមចំប៉ាមួយដើមយ៉ាងធំចោលម្លប់ត្រឈឹងត្រឈៃ និងមានក្លិនផ្កាក្រអូបពិដោរទៀតផង ។ បន្ទាប់ពីក្រុមអ្នកទេសចរទស្សនាទិដ្ឋភាពផ្សេងៗរួចហើយបន្តដំណើរទៅងូតទឹកជ្រោះធ្លាក់ពីកំពូលភ្នំមិនចេះរីងស្ងួត ត្រូវបានមនុស្សម្នា ទៅងូតលេងមិនចេះឆ្អែតឆ្អន់នូវទឹកដ៏ថ្លាឈ្វេង ត្រជាក់ដូចទឹកអម្រឹត ។

ទឹកជ្រោះដែលធ្លាក់នេះគេសង្កេតឃើញមានពីរផ្នែក គឺផ្នែកទី1 មានកម្ពស់ពី5ទៅ6 ម៉ែត្រ ដែលមានមុខកាត់ទឹកហូរប្រមាណពី10 ទៅ15ម៉ែត្រ (ផ្នែកខាងលើ) និងផ្នែកទី2 ឬទិដ្ឋភាពទឹកធ្លាក់ខាងក្រោម មានកម្ពស់ទឹកធ្លាក់ពី15ទៅ20ម៉ែត្រ មានមុខកាត់ពី6ទៅ8ម៉ែត្រ ទឹកធ្លាក់នោះហូរខ្ជួបប្រាំង ខ្ជួបវស្សា ចេញពីលើខ្នងភ្នំដែលគេពិបាកនឹងរកប្រភពនៃទឹកហូរចេញចូលទាំងនេះណាស់ គេមានកសាងនូវបង្កាន់ដៃសំរាប់ការពារគ្រោះថ្នាក់ផងដែរ ។ អ្នកដែលបានទៅឃើញទេសភាពភ្នំគូលែន គឺពួកគេហាក់ដូចជា មានអារម្មណ៍ចម្លែកក្នុងចិត្ត ហើយរំភើបយ៉ាងខ្លាំងមានជំនក់ចិត្តនឹងសម្រស់ធម្មជាតិនៅទីនោះ ដោយកោតសរសើរមិនដាច់ពីមាត់ ។

លោក ស៊ិន ម៉េន ឱ្យដឹងថា រមណីយដ្ឋាន ភ្នំគូលែន ត្រូវបានរៀបចំមានអនាម័យបរិស្ថានល្អមិនធ្វើឱ្យប៉ះពាល់ដល់សម្រស់ធម្មជាតិនៅទីនោះឡើយ ហើយក្រុមអ្នកទេសចរម្នាក់ៗ ហាក់ដូចជាមានការភ្ញាក់រលឹកដល់សម្រស់ធម្មជាតិនៅទីនោះ ដោយពួកគេម្នាក់ៗក៏មានការចូលរួមថែរក្សាចំពោះបរិស្ថានផងដែរ ។ នៅថ្ងៃឈប់សម្រាក ឬថ្ងៃបុណ្យប្រពៃណីជាតិ និងអន្តរជាតិម្តងៗ គេសង្កេតឃើញភ្ញៀវទេសចរជាតិ-អន្តរជាតិទៅទស្សនា យ៉ាងច្រើន ដោយមានរថយន្ត ម៉ូតូបើកឡើងទៅដល់គោលដៅ មានកន្លែងទុកដាក់ត្រឹមត្រូវនិងម៉ោងសម្រាប់ឡើងចុះទៀតផង គឺចៀសវាងគ្រោះថ្នាក់ចរាចរកើតឡើងដោយយថាហេតុ ។

អតីតរាជធានីដំបូងនៅសម័យមហានគរលើកំពូល ភ្នំគូលែន ដែលពីមុនជាកន្លែងប្រារព្ធពិធីទេវរាជក្នុង សាសនាព្រហ្មញ្ញ បច្ចុប្បន្នបានក្លាយជាវត្តអារាមសម្រាប់គោរពបូជា និងជារមណីយ-ដ្ឋានធម្មជាតិដ៏ស្រស់បំព្រង ដែលទាក់ទាញអារម្មណ៍អ្នកទេសចរឱ្យទៅកំសាន្តយ៉ាងច្រើនកុះករ ដោយជួយលើកស្ទួយជីវភាពប្រជាពលរដ្ឋ ក្នុងតំបន់សេដ្ឋកិច្ចជាតិបានប្រសើរមួយកំរិត ៕





# NEW ASIA AMERICA TRAVEL, INC.

## Domestic & International Travel Services

Serve all major airlines: បំរើលោកអ្នកដោយក្រុមហ៊ុនអាកាសចរសំខាន់ៗជាច្រើន
Tours-cruises រៀបចំដំណើរកំសាន្ត "ទួ" តាមនាវាចរ
Reentry permits/visa លិខិតទិដ្ឋាការ "រីអិនទ្រី ភើមីត"
Passport photos រូបថតដាក់លិខិតឆ្លងដែន
Honeymoon packages – specials ទេសចរណ៍ស្វាមីភរិយាថ្មីថ្មោងពិសេស
Single paper
Special Group Tours រៀបចំធ្វើដំណើរពិសេសជាមួយក្រុម
Walt Disney 4-8 days ដំណើរទៅ "វាល់ឌីសណេ" ៤-៨ថ្ងៃ
Las Vagas 4-7 days ដំណើរទៅ "ឡាសវេហ្គាស" ៤-៧ថ្ងៃ
California 7-10 days ដំណើរទៅ "កាលីហ្វ័រនីញ៉ា" ៧-១០ ថ្ងៃ
Hawaii 6-14 days ដំណើរទៅ "ហាវ៉ៃ" ៦-១៤ថ្ងៃ
Caribbean –Mexico ដំណើរទៅ "ខារីប៊ាន-មិកស៊ិក"
Europe 7-21 days ដំណើរទៅ "អឺរ៉ុប" ៧-២១ថ្ងៃ
Asia: China, Hong Kong, ដំណើរទៅអាស៊ី :ចិន,ហុងកុង
Singapore, Malaysia, ដំណើរទៅ សិង្ហបុរី
Thailand, Cambodia 10-21 days. ដំណើរទៅប្រទេសថៃ-កម្ពុជា ១០-២១ថ្ងៃ
Money Transfer (Vietnam only) ផ្ញើការផ្ញើប្រាក់ (វៀតណាមប៉ុណ្ណោះ)
Citizenship test ផ្ញើតេស្តសំរាប់ចូលសញ្ជាតិ
Pin and Pinless phone cards. មានកាតទូរស័ព្ទ មានលេខសម្ងាត់ ឬគ្មាន

Dung Phat Plaza Tel: (215) 468-7876
1110 Washington Ave., #6 Fax: (215) 468-7917
Philadelphia, PA 19147 E-mail: info@naatravel.com
www.newasia-americatravel.com

# The Noni Juice

ទឹកផ្លែមផ្លែ "ណូនី" ខ្មែរហៅផ្លែ "ញ" ត្រូវគេចងចាំថា ឪពុកម្តាយ ឬដូនតា ធ្លាប់យកផ្លែ "ញ" នេះទៅត្រាំស្រា ហើយពិសារជាថ្នាំព្យាបាលការឈឺចុកចាប់នានា បណ្តាលឱ្យមានកម្លាំង-ចុះកម្លាំងឈាម ។ល។ ឥឡូវនេះ អ្នកវិទ្យាសាស្ត្រខាងពេទ្យរកឃើញថា ផ្លែ "ញ" នេះ បើប្រើឱ្យសមត្ថភាពលាយជាតិតិចមិនធ្វើឱ្យចុះសម្ពាធឈាមបន្ថយការឈឺសន្លាក់ដៃជើងព្យាបាលជំងឺទឹកនោមផ្អែម-ធ្វើឱ្យមានកម្លាំង និងជួយរំលាយអាហារទៀតផង។
សូមទាក់ទងតាមឈ្មោះ និងទូរស័ព្ទខាងក្រោម ដើម្បីជាវទឹកផ្លែម "ណូនី"



Philadelphia: David: 215-268-4821 or Jason: 215-805-3396
Rhode Island: Hui Le: 401-640-5158
Lowell: Samran: 508-216-6062
The Noni Jucie is made by traditional method, 100% pure, and no preservation. It can help decrease high blood pressure; reduce arthritis pain, diabetes, increase body energy level and digestion system.




# Phở 488

320 W. Oregon Avenue. Suite 1. Philadelphia, Pa 19148
Tel. 215-952-6688
Open: 7 days a week. Sunday – Thursday: 9a.m.–9 p.m.
Friday & Saturday: 9a.m. –10 p.m.




បើកទទួលភ្ញៀវរៀងរាល់ថ្ងៃចាប់ពីម៉ោង ៩ ព្រឹក ‿ម៉ោង ៩ ល្ងាច
លើកលែងតែថ្ងៃសុក្រ និងសៅរ៍ បើករហូតដល់ ១០ យប់











- យើងមានមុខម្ហូបសំរាប់ពិសារបាយ មាន គុយទាវ មាននំបញ្ចុក ហើយ ជាពិសេសមានធ្វើ "ហ្វឺ" គ្រប់មុខ ជូនពិសារយ៉ាងឈ្ងុយឆ្ងាញ់
- បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ រងចាំបំរើអតិថិជនមិនឱ្យខុសបំណងឡើយ

តមកពីទំព័រទី០៤

## បទសម្ភាសន៍ជាមួយតំណាងរាស្ត្រ...

**ចម្លើយ ឃែម បុញ្ញារិទ្ធ :** ខ្ញុំរួមដំណើរមក ស.រ.អា នេះ ជាមួយលោក កឹម សុខា ដើម្បីមកជួបតំណាងរាស្ត្រ ព្រឹទ្ធសមាជិក និងរដ្ឋាភិបាលអាមេរិកាំង ដើម្បីសិក្សាយល់ដឹងពីប្រទេសរបស់គេ ហើយនឹងប្រាប់គេពីស្ថានការណ៍ទាំងឡាយនៅកម្ពុជាឱ្យគេដឹងមានរាប់ទាំងធនាគារពិភពលោក និងអង្គការផ្សេងៗឯទៀត ជាច្រើនចំនួនរយៈពេល៩សប្តាហ៍ ។

**សំនួរ :** មកជួបសភាអាមេរិកាំង តើគណបក្សសិទ្ធិមនុស្សចង់ប្រាប់គេអ្វីខ្លះទៅ ?

**ចម្លើយ :** ជាការពិតទៅយើងមកសិក្សាអំពីប្រទេសរបស់គេទេ គេបានពន្យល់អំពីលទ្ធិប្រជាធិបតេយ្យនៅ ស.រ.អា អ្វីដែលយើងបានកត់សម្គាល់សំខាន់មែនទែន គឺភាពទូលំទូលាយនៃវិស័យព័ត៌មាន គេមិនមានការលាក់បាំងអ្វីទាំងអស់ ឧទាហរណ៍ ដូចជា CRS គេរៀបចំឯកសារលក្ខណៈច្បាស់លាស់ជូនសមាជិកតំណាងរាស្ត្ររបស់គេ ដើម្បីធ្វើសេចក្តីព្រាងច្បាប់អ្វីមួយៗ គេបានសិក្សាច្បាស់លាស់មែនទែន ។ ចំណុចមួយទៀត ដែលគួរឱ្យកត់សម្គាល់ គឺការបែងចែកអំណាចដាច់ពីគ្នា រវាងអំណាចនិតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ក្រៅពីនេះ ខ្ញុំសង្កេតឃើញថា មុននឹងអនុម័តច្បាប់នីមួយៗ គេតែងជួបពិភាក្សាជាមួយប្រជាពលរដ្ឋជាមួយគណបក្សធំតូច និងមានការអនុម័តច្បាប់ ។

**សំនួរ :** តើលោកមានការផ្តាំផ្ញើអ្វីខ្លះ ដល់ប្រជាពលរដ្ឋខ្មែរដែលធ្លាប់គាំទ្រលោកនាពេលនេះ?

**ចម្លើយ :** ឆ្លៀតឱកាសនេះ ខ្ញុំសូមអរគុណដល់ប្រជាពលរដ្ឋនៅទីនេះ ដែលមានការគាំទ្រយ៉ាងសកម្មទៅប្រទេសកម្ពុជាពីទីនេះទៅ ហើយសូមបងប្អូនទាំងស្រីប្រុស ចាស់ ក្មេង មេត្តាជួយជាបន្តទៅទៀត ពីព្រោះយើងលំបាកមែនទែនដោយមានបញ្ហាយ៉ាងច្រើន ដែលត្រូវដោះស្រាយនៅកម្ពុជា ។

**សុបិន :** សូមជូនពរឱ្យបានជោគជ័យ សូមអរគុណ !

**នៅពេលជាមួយគ្នានោះ សុបិន ថាច់ បានទៅស្រង់យោបល់របស់សកម្មជននយោបាយ ដែលបានមកជួបជុំនៅទីនោះ ។**

៣- មាស ជា សកម្មជនគណបក្ស សម រង្ស៊ី



ខ្ញុំមានសេចក្តីរីករាយដោយបានចូលរួមជួបជុំគ្នាជាមួយគណបក្សសិទ្ធិមនុស្សនេះជាឱកាសដ៏ល្អ ដែលបានកើតឡើង ដើម្បីឱ្យយើងស្វែងយល់គ្នាទៅវិញទៅមកបាន។

**៤-** អ៊ុម លឿង ដំណាងគណបក្សសិទ្ធិមនុស្សប្រចាំហ្វីឡាដែលហ្វីយ៉ា :





ខ្ញុំសប្បាយចិត្តដោយយើងបានជួបជុំគ្នាឱ្យកម្លាំងចិត្តដល់លោកប្រធាន កឹម សុខា ដែលបានអញ្ជើញមកដល់សាខាយើង ហើយខ្ញុំក៏សប្បាយចិត្តណាស់ដែរ ដែលបានទទួលសកម្មជនគណបក្ស សម រង្ស៊ី ក្នុងពិធីជប់លៀងរបស់យើងនេះជាសញ្ញានៃការរួបរួមកម្លាំងគ្នាបាននៅហ្វីឡាដែលហ្វៀយើងនេះ ។

៥- វិសាកា ពេជ្រ តំណាងគណបក្សសិទ្ធិមនុស្សនៅឆ្នេរខាងកើតស.រ.អា :



ការពិតទៅ គឺយើងបានធ្វើការជួបជុំគ្នារបៀបនេះ១ខែម្តង តែលើកនេះមានភាពអ៊ូអរជាងមុនៗ ដោយសារលោកប្រធានអញ្ជើញចូលរួម ហើយក៏មានតំណាងគណបក្ស សម រង្ស៊ី ចូលរួមផងដែរ ។

**៦-** ញូយ ចំរើន ដំណាងគណបក្សសិទ្ធិមនុស្សទ្វីបអាមេរិកខាងជើង

ខ្ញុំមានការសង្កេត ឃើញការរីកចំរើននៅហ្វីឡាដែលហ្វីយ៉ា មាន ទាំងសមាជិក និងចំនួនថ្នាក់ដឹកនាំ ហើយប្រជាជនយើងមានសកម្មភាពក៏ច្រើន ដូចនេះឃើញថា យើងមានសកម្មភាពល្អ ។

គោលការណ៍របស់គណបក្សសិទ្ធិមនុស្ស ពុំមែនតែជម្រុញឱ្យចំរើនតែគណបក្សតែមួយប៉ុណ្ណោះទេ គឺឱ្យចំរើនទាំងអស់គ្នា ។ រៀងរាល់ខែយើងរៀបចំការប្រជុំ ហើយអញ្ជើញសាធារណជនមកចូលរួម នេះក្នុងន័យរករូបមន្តឱ្យបានដឹងរឿង ជួយក្នុងស្រុកផង និងជួយសង្គមខ្លួនឯងផង ។

យើងឃើញមានការប្រែប្រួលក្នុងសង្គមយើងក៏មានក្នុងគណបក្សក៏មាន ជាពិសេសយើងឃើញមានចំណងសាមគ្គីភាពរវាងគណបក្ស និងសង្គម ហើយដែលសំខាន់ គឺដល់សង្គមខ្មែរក្រោម ដែលយើងបានចាត់ទុកថាជាបងប្អូន ហើយជាមួយលោកប្រធានថ្ងៃនេះ ទោះជាកំពុងនៅ វ៉ាស៊ីនតុន ក៏ត្រូវនាំគ្នាមកចូលរួមពិធីខួបទី ៦០ នៃការកាត់ផ្តាច់ដីខ្មែរក្រោមទៅឱ្យយួន ទោះជាឆ្ងាយប៉ុណ្ណា ក៏យើងត្រូវតែទៅ ព្រោះជាសាច់ជាឈាមយើង ៕ **បទយកការណ៍របស់ សុបិន ថាច់**


# Randolph C. Smith




Attorney at Law
267-324-6503

Office # 1
1819 JFK Blvd.
Philadelphia, Pa 19103

Office # 2
1115 S. 11th St.
Philadelphia, Pa 19147

ការិយាល័យច្បាប់យើងខ្ញុំ មានចំនាញខាងករណី គ្រោះថ្នាក់រថយន្ត
☞ ការរបួសនៅកន្លែងធ្វើការ ☞ បើកបរក្រោមឥទ្ធិពលស្រវឹង
☞ ករណីឧក្រិដ្ឋកម្ម និងអន្តោប្រវេសន៍ យើងនឹងយកចិត្តទុកដាក់ពីរថយន្តពីអ្វីទាំងអស់ដោយមិនឱ្យលោកអ្នកចំណាយប្រាក់ខ្លួនឯងឡើយ ។
បើចង់ដឹងអ្វីបន្ថែមសូមហៅរក **សុធា : (267) 324-6503**

We are specialty in Car Accident, Work Injury, DUI, Criminal Matter, and Imminration.

We will take care of your car and everything else without your pochet expense.
Please contact Sothia at 267-324-6503 for more information.



# Nationwide

Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147



ទំពាំងបាយជូរ គឺជាផ្លែឈើដែលមានរសជាតិផ្អែមជូរ និងមានដាក់លក់នៅលើទីផ្សារទូទៅ ហើយត្រូវបានគេចាត់វាទុកជាអាហារបំប៉នមួយប្រភេទ ។ ដែលក្រៅពីមានគុណប្រយោជន៍ខាងអាហារហើយនោះ ក៏នៅមានគុណភាពខាងឱសថជាច្រើនយ៉ាងទៀតផង ។

# អត្ថប្រយោជន៍ នៃផ្លែទំពាំងបាយជូរ

●●●សារជាតិអាហារសំខាន់នៅក្នុងទំពាំងបាយជូរ គឺស្ករ និងសារជាតិពពួកអាស៊ីតប្រមាណចាប់ពី៧-៨ប្រភេទបន្ថែមទៀត ។ ក្រៅពីនេះ នៅមានក្លូកូស សូខូលACID CITRIC វីតាមីន C ព្រមទាំងដែក និងកាល់ស្យូម ។

ការទទួលទានផ្លែទំពាំងបាយជូរបានជាប់ជាប្រចាំ មានប្រសិទ្ធភាពជួយប៉ូវខួរក្បាល ប៉ូវបេះដូង ទម្លាក់ស្ត្រេស បំបាត់អាការស្រេក ប៉ូវកម្លាំង និងសំរាប់មនុស្សមានរាងកាយស្គមស្គាំង ចាស់មុនវ័យ ពុំមានកម្លាំងកំហែងជាដើម ។ ប្រសិនបើបានទទួលទានទំពាំងបាយជូររាល់ថ្ងៃ នឹងជួយឱ្យរាងកាយសន្សឹមៗឡើងមាំមួនមកវិញបាន ។

លើសពីនេះទៅទៀត ផ្លែទំពាំងបាយជូរគេនាំយកទៅផលិតជាស្រាទំពាំងបាយជូរដែលជាប្រភេទស្រាប៉ូវបំប៉នទៀតផង ។ ចំណែក ទង ដើម និងឫស អាចយកទៅធ្វើជាថ្នាំបុរាណសំរាប់បណ្តេញខ្យល់ ទម្លាក់ស្ត្រេស ព្យាបាលរោគរលាកសន្លាក់ ឈឺឆ្អឹង ឆ្អែង ឈឺសរសៃសរសួង រមួលសរសៃប្រសាទ បំបាត់អាការឈឺចាប់ និងអាចបំបាត់អាការក្អួតបានទៀតផង ។

ក្បួនតម្រាសំរាប់ធ្វើជាឱសថតាមបែបផែនបុរាណចិនមានដូចតទៅ :

**ឈឺតាមសន្លាក់ឆ្អឹង :** ឫសទំពាំងបាយជូរនៅស្រស់ ៦០-៩០ក្រាម ចិញ្ច្រាំឱ្យល្អិត ដាក់រួមជាមួយប្រអប់ជើងជ្រូកម្ខាង រួចប្រើស្រាសជាមួយ និងទឹកក្នុងបរិមាណស្មើគ្នា ដាំទឹកឱ្យពុះទុកទទួលទាន ។

**រោគរលាកថ្លើម ខាន់លឿង និងអាការរលាកឈឺនៅតាមសន្លាក់ :** យកឫសទំពាំងបាយជូរនៅស្រស់ពី ៣០-៩០ក្រាមដាំទឹកទទួលទាន ។

**ខ្វះឈាម វិលមុខ ញ័របេះដូង :** ទទួលទានស្រាទំពាំងបាយជូរក្នុងបរិមាណមួយសមល្មមក្នុងមួយថ្ងៃ ២-៣ដងជាប្រចាំ ។

**ស្ត្រីចាញ់កូន ហើមទឹកនោមទាស់ :** យកឫសទំពាំងបាយជូរនៅស្រស់ ៣០ក្រាម ដាំទឹកទទួលទាន ៕

# គណបក្សប្រជាជននៅហ្វីឡារកលុយជួយយកងទ័ព

ដោយ អ៊ុំមឿង

●●●ចលនានៃការរ៉ៃអង្គាសប្រាក់សម្រាប់ជួយដល់យុទ្ធជននៅលើសមរភូមិប្រយុទ្ធ ជាពិសេស នៅមុំប្រាសាទព្រះវិហារ តែងតែកើតមានជាប្រចាំ ចាប់តាំងពីមានការឈ្លានពានពីសំណាក់កងទ័ពសៀម មកលើបូរណភាពទឹកដីខ្មែរ នាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៨ មក ។



លោក សៀ កុសល ស្ថានបេសកកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ



ហែម ហេង ឯកអគ្គរាជទូតខ្មែរប្រចាំសហរដ្ឋអាមេរិក

សកម្មភាពនៃអង្គាសនេះ ត្រូវបានពលរដ្ឋខ្មែរស្នេហាជាតិ ធ្វើជាហូរហែរ ទោះជាខ្មែរនៅក្នុងប្រទេសក្តី និងខ្មែរនៅក្រៅប្រទេសក្តី ហើយជាពិសេស ចលនានេះតែងតែកើតឡើងជារឿយៗនៅក្នុងសហគមន៍ខ្មែររស់នៅ ដែលមាននៅតាមរដ្ឋនានារបស់សហរដ្ឋអាមេរិកតែម្តង ។

ថ្មីៗកន្លងមកនេះសមាជិក សមាជិការបស់សាខាគណបក្សប្រជាជនកម្ពុជា ប្រចាំទីក្រុងហ្វីឡាដែលហ្វៀ ក៏បានប្រារព្ធពិធីលៀងសាយភោជមួយ ដើម្បីប្រមូលថវិកាសម្រាប់ជួយសម្រួលដល់ផ្នែកខ្លះៗ របស់កងទ័ពខ្មែរ ដែលកំពុងមានភារកិច្ចការពារបូរណភាពទឹកដី នៅតំបន់កំពុងមានវិវាទនាមុំប្រាសាទព្រះវិហារ ។

អង្គពិធីបានប្រារព្ធយ៉ាងសមរម្យ ដោយមានការរាំលេងកម្សាន្តជាមួយក្រុមភ្លេងវាយោតន្ត្រីក្រោមពន្លឺភ្លើងអគ្គិសនី ដែលបានតុបតែងឡើងយ៉ាងល្អប្រណិត នៃភោជនីយដ្ឋាន ហៃទៀង ស្ថិតនៅតំបន់ហ្វីឡាដែលហ្វៀខាងត្បូង កាលពីរាត្រីថ្ងៃសៅរ៍ ទី ៣០ ខែឧសភា កន្លងមកនេះ ។

លោក សុខ យុទ្ធ បាននិយាយថា គណៈកម្មការរបស់លោក និងចាត់តំណាងម្នាក់ក្នុងការយកថវិកាទាំងនោះទៅចាត់ចែងដល់កងទ័ពដោយផ្ទាល់ដៃ ដោយមានការទិញជាសម្ភារៈប្រើប្រាស់ខ្លះ និងគ្រឿងឧបភោគ-បរិភោគខ្លះ ដូចជា មី ត្រីខកំប៉ុង ជាដើម និងថវិកាខ្លះៗ ក្នុងការជួយសម្រួលដល់បន្ទុកគ្រួសារ ។

លោក សុខ យុទ្ធ បន្តថា គោលបំណងរបស់គណកម្មការរៀបចំពិធីក៏ដូចជាពលរដ្ឋខ្មែរទូទៅ គឺចង់បង្ហាញអំពីការលើកទឹកចិត្ត និងពង្រឹងដល់ស្មារតីយុទ្ធជនដែលកំពុងបំពេញបេសកកម្មលើខ្សែត្រៀមប្រយុទ្ធក្នុងបុព្វហេតុជាតិមាតុភូមិ និងម្យ៉ាងទៀតជាការបង្ហាញថា ទោះជាខ្មែរនៅក្រៅប្រទេសក្តី ក៏មានទឹកចិត្តចំពោះភារកិច្ចជាតិមាតុភូមិយើងដែរ ។

គេសង្កេតឃើញមានវត្តមាននៃឥស្សរៈជនសំខាន់ៗមកពីគណបក្សប្រជាជនកម្ពុជាមួយចំនួនដែលបានចូលរួមក្នុងអង្គពិធីដូចជាលោក ហែម ហេង ឯកអគ្គរាជទូតខ្មែរ ប្រចាំសហរដ្ឋអាមេរិក លោក សៀ កុសល ស្ថានបេសកកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ , លោក អ៊ូ សុវណ្ណ អគ្គកុងស៊ុលប្រចាំសហរដ្ឋអាមេរិក និងជាអតីតអ្នកសារព័ត៌មាន "សំឡេងយុវជនខ្មែរ" ដែលធ្លាប់ជាអ្នកកាសែតក្នុងស្រុក មាននិន្នាការប្រឆាំងរដ្ឋាភិបាល (តទៅទំព័រទី១៩)

# ហេតុអ្វីអ័ក្សនៃផែនដីទ្រេតយ៉ាងនេះ?

ដោយ : គីមភៀន

●●●តាមការពិតផែនដីយើង ដែលបារាំងហៅថា " globe terestre "នោះ មានរាងមូលដូចផ្លែក្រូច ហើយថិតនៅក្នុងប្លង់អាកាសមួយកាត់ផែនដីជាពីរបំណែកស្មើគ្នា នៅត្រង់អេក្វាទ័រ ។ ផែនដីនេះវិលជុំវិញខ្លួនឯងមួយថ្ងៃ (២៤ម៉ោង) បានមួយជុំ រួចហើយវិលជុំវិញព្រះអាទិត្យតាមវិថីមួយ ដែលមានរាងជាពងក្រពើ ។ ផែនដីនេះវិលជុំវិញអ័ក្ស ស្រមៃមួយដែលមានភាពទ្រេតពីកើតទៅលិច ទៅតាមវិថីគោចរនេះ បានមួយជុំក្នុងរយៈពេល១ឆ្នាំ ។

មកពីគេយល់យ៉ាងនេះហើយ បានជាគេធ្វើរូបផែនទីទ្រង់ទ្រេតផ្សៀងយ៉ាងនេះ ។

ថ្ងៃនោះមានគណៈកម្មការមួយក្រុម ចុះពីខេត្តមកពិនិត្យសាលាវិទ្យាល័យមួយនៅស្រុក ហើយបានដើរពិនិត្យតាមថ្នាក់និមួយៗ ។

សិស្សថ្នាក់និមួយៗមានការភ័យខ្លាចណាស់ ខ្លាចលោគ្រូសួរដោយគណៈកម្មការ ហើយឆ្លើយមិនត្រូវ លោកគ្រូប្រចាំថ្នាក់របស់ខ្លួន និងស្តីបន្ទោសនៅពេលក្រោយ ។

លោកប្រធាននៃគណៈកម្មការ សួរទៅសិស្សទាំងអស់គ្នាថា :

- ប្អូនៗ សិក្សាពីមុខវិជ្ជាអីនៅម៉ោងនេះ ?

សិស្សឆ្លើយព្រមគ្នា :

- មុខវិជ្ជាភូមិសាស្ត្រ លោកគ្រូ !

លោកប្រធានក៏សម្លឹងទៅឃើញរូបផែនដីកំពុងដាក់បញ្ឈរនៅលើតុគ្រូ ។ គាត់ក៏ចង្អុលទៅរូបផែនដី ហើយសួរទៅសិស្សអង្គុយមុខគេ :

- ចុះផែនដីនេះ ម៉េចក៏ទ្រេតវៀចទៅម្ខាងយ៉ាងហ្នឹង ? ។ សិស្សនោះភ័យ ស្មានថាគេសួររកមុខសិស្សណា បានធ្វើឱ្យអ័ក្សផែនដីទ្រេត ។ ក៏ប្រញាប់ឆ្លើយយករួចខ្លួន :

- ទេ ! លោកគ្រូ ខ្ញុំគ្មានបានដើរទៅជិតផែនដីនោះទេលោកគ្រូ !

គាត់ចង្អុលទៅប្អូនបន្ទាប់ ដោយសួរសង្កត់ធ្ងន់ទៀតថា :

- ចុះប្អូននេះ មានបានដឹងថា មកពីហេតុអ្វីបានជាអ័ក្សនេះ ផ្សៀងទ្រេតយ៉ាងនេះទេ ?

- ជម្រាបលោកគ្រូ ! ពួកវាក៏ដឹងគ្រប់គ្នាថា ខ្ញុំដើរចូលមកក្នុងថ្នាក់ក្រោយគេបំផុត វាច្បាស់ជាដឹងថា ខ្ញុំពុំបានប៉ះពាល់ធ្វើឱ្យអ័ក្សនោះផ្សៀងទ្រេតយ៉ាងនេះទេ ។ មិនអស់ចិត្ត លោកគ្រូប្រធានសួរបន្ថែមទៅសិស្សម្នាក់ទៀត :

- ទេ លោកគ្រូ ! ខ្ញុំមិនដឹងបុព្វហេតុណា ឬអ្នកណាមួយធ្វើឱ្យផ្សៀងទ្រេតយ៉ាងនេះទេ ! ឃើញវាទ្រេតយ៉ាងនេះ តាំងពីមុនមក ! ។

លោកគ្រូប្រចាំថ្នាក់ចង់ "សូវេ " ជួយសង្គ្រោះសិស្សរបស់ខ្លួន ក៏ឆ្លើយកាត់ថា :

- សុំទោសលោកចាងហ្វាយអប់រំខេត្ត សិស្សទាំងអស់នេះពុំបានដឹងថា អ្នកណាបានធ្វើឱ្យអ័ក្សផែនដីនេះ ផ្សៀង ទ្រេតយ៉ាងនេះទេ ។ ដោយពុំបានពិនិត្យ ខ្ញុំបានទិញមកពីបណ្ណាគារ ផែនដីនេះបានទ្រេតស្រាប់ទៅហើយ ។

លោកប្រធានគណកម្មការហួសចិត្ត សម្លឹងលោកគ្រូប្រចាំថ្នាក់មួយសន្ទុះ រួចសួរសំនួរថ្មីមួយទៀតទៅសិស្សអង្គុយក្រោយគេឈ្មោះ ប្លុយ :

តើប្អូនមានដឹងចំនួនប្រជាពលរដ្ឋកម្ពុជាបច្ចុប្បន្ននេះ មានប៉ុន្មានលាននាក់ទេ ?

- បាទលោកគ្រូ មាន ១៤ លាននាក់ ។

សិស្សឈ្មោះភ្លុកអង្គុយក្បែរនោះ ក្រោកឈរឆ្លើយកាត់ :

- មិនមែនទេ ! នៅជិតផ្ទះខ្ញុំទើបកើតកូនភ្លោះមួយគូ កាលពីម្សិលមិញ ! ខ្មែរមានប្រជាពលរដ្ឋឡើងដល់ ១៤លាន ២នាក់ហើយ ! ៕

កំណាព្យ

# ជីវិតយុទ្ធជនខ្មែរ ព្រោះស្នេហ៍ជាតិ

*ដោយ : ម៉ម យឿន*

អតីតយុទ្ធជនខ្មែរស្ម័គ្រចិត្ត    រួមកាយជិតស្និទ្ធចូលរួបរួម
ជាមួយយុទ្ធជនបានព្រៀងព្រម    អាមេរិកជាធំផ្តល់ឱ្យសិទ្ធិ ។
យុទ្ធជនជាតិខ្មែរកាលសម័យ    ប្រយុទ្ធស៊ូក្ស័យព្រោះជាតិពិត
ស្រឡាញ់ឯករាជ្យស្មើជីវិត    ស៊ូរួមកាយចិត្តចាប់អាវុធ ។
ចូលធ្វើយុទ្ធជនខ្មែរអង់អាច    តាំងចិត្តមិនខ្លាចចូលប្រយុទ្ធ
ជាមួយសត្រូវមានពុតត្បុត    លោភលន់បំផុតបំពានច្បាប់ ។
មាតុភូមិជាតិខ្មែរបានរងទុក្ខ    ព្រោះខ្មាំងអុកឡុកប្រចាំជាប់
រាប់រយឆ្នាំហើយខ្មែរបានស្លាប់    ជាប់ជាលំដាប់ពុំល្ហែល្ហើយ ។
ជាតិយួនជាតិសៀមត្រៀមជានិច្ច    ចងលតែកំទេចមិនទុកឱ្យ
ជាតិខ្មែរនៅរស់បានទៀតឡើយ    ជាតិខ្មែរធ្លាក់ខ្សោយយួនសៀមឈ្នះ ។
យុទ្ធជនខ្មែរខ្លាំងតាំងសច្ចា    ដោយចិត្តហ៊ានក្លាស៊ូបង់លះ
មិនឱ្យយួនសៀមចិត្តមានះ    ចង់ធ្វើជាម្ចាស់ត្រួតត្រាខ្មែរ ។
យុទ្ធជនខ្មែរត្រង់ចំពោះជាតិ    ទឹកចិត្តល្អស្អាតចិត្តស្និទ្ធស្នេហ៍
ចិត្តគ្មានបោះបង់ហើយប្រួលប្រែ    ស៊ូស្លាប់ឱ្យតែជាតិខ្មែររស់ ។
យុទ្ធជនប្រយុទ្ធយ៉ាងប្តូរផ្តាច់    លំបាកដូចម្តេចនៅតែស្មោះ
វាយខ្មាំងសត្រូវគ្មានខ្លាចសោះ    គឺដោយពីព្រោះស្នេហាជាតិ ។
ពេលខ្មាំងវាយខ្លាំងយុទ្ធជនខ្មែរ    ចិត្តគ្មានស្លុតទេតែប្រុងស្មៀត
រកល្បិចបាញ់ខ្មាំងចាក់ពិឃាដ    ខ្មាំងស្លាប់ច្រើនទៀតចុះចាញ់ដៃ ។
ពេលជាប់ប្រយុទ្ធខ្មាំងតែងតែ    បាញ់មកលើខ្មែរខ្លាំងក្លាក្រៃ
តែយុទ្ធជនខ្មែរមិនសំចៃ    វាយខ្មាំងឱ្យក្ស័យបានជ័យជោគ ។
អាវុធគ្រប់ចុនបាញ់សន្ធាប់    ទាំងថ្ងៃទាំងយប់ក្នុងជម្រក
យុទ្ធជនត្រៀមស្រេចពេលខ្មាំងមក    វាយតបសង្ស្របយ៉ាងអង់អាច ។
ឱយុទ្ធជនខ្មែរគ្រប់សម័យ    តែងលំបាកក្រៃតែមិនខ្លាច
តស៊ូការពារសិទ្ធអំណាច    ជាខ្មែរអ្នកប្រាជ្ញពូជអ្នកជា ។
ជីវិតយុទ្ធជនបានបាត់បង់    ព្រោះចិត្តស្មោះត្រង់ហើយហានក្លា
គួរណាស់មេនាំមានមេត្តា    ដល់ចិត្តកាយាយុទ្ធជនផង ។
មិនត្រូវមានចិត្តគិតតែខ្លួន    ឯងបានធំធូនរួចគ្រប់គ្រង
ដោយប្រើអំណាចតាមបំណង    ចេតនាប៉ុងប៉ងប្រើអំណាច ។
ភ្លេចអស់យុទ្ធជនដែលបានច្បាំង    ប្រយុទ្ធតតាំងយ៉ាងអង់អាច
ទៅលើពួកខ្មាំងចិត្តបីសាច    ចិត្តវាតោងកាចប្លន់ទឹកដី ។
ដីខ្មែរជាតិខ្មែរបានបាត់បង់    ព្រោះមេមិនត្រង់ទៅចូលដៃ
ជាមួយនិងខ្មាំងឱ្យប្រល័យ    ខ្មែរស្លាប់អស់ដីរួមនៅតូច ។
មេដឹកនាំខ្មែរនៅមិនស្កប់    នៅតែធ្វើជាប់ចិត្តវិលខូច
ចូលដៃសត្រូវជាប់ស្នូពូជ    មេខ្មែរផ្តើមផ្តួចសម្លាប់គ្នា ។
ជាតិខ្មែរស្លាប់អស់ព្រោះមេក្បត់    ជាតិឯងប្រាកដត្រូវវេទនា
អស់សិទ្ធអំណាចអស់ភារា    យុទ្ធជនគ្រប់គ្នាវេទនាណាស់ ។
យុទ្ធជនក្រៅស្រុកចិត្តក្រៀមក្រំ    លើកដៃប្រណម្យសូមបន់ព្រះ
ជួយថែរក្សាឱ្យបានឈ្នះ    បានសុខសាន្តច្បាស់តរៀងទៅអើយ ៕

## តមកពីទំព័រទី០៣ ថ្នាក់ដឹកនាំ...

តើលក្ខណៈសម្បត្តិនៃអ្នកទាំងនោះមានអ្វីខ្លះ ដែលគេអាចសំគាល់បានយ៉ាងដូច្នេះ ? នៅក្នុងទ្រង់ទ្រាយនៃការអប់រំនៅ ស.រ.អា នេះ គេមិនបានទទួលស្គាល់លក្ខណៈសម្បត្តិដែលទទួលពីកំណើត ដូចជា កូនមន្ត្រី កូនស្តេច កូនអ្នកមាន ឬអ្នកមានបុណ្យណា ថាជា "មេដឹកនាំ"នោះឡើយ មុននឹងធ្វើសកម្មភាពយ៉ាងជាប់លាប់យ៉ាងទៀងទាត់អស់រយៈពេលយូរបញ្ជាក់គំរូនៃអំពើល្អរបស់ខ្លួន ។ គឺអំពើរបស់ ឬប្រចាំបុគ្គលដែលចែកផ្លូវគ្នាដើររវាងល្អ និងអាក្រក់ដែលអាចឱ្យគេឯងកត់សម្គាល់បាន នៅពេលអនុវត្តន៍អស់ពេលដ៏យូរ ។ លក្ខណៈដំបូងបង្អស់ នៃ"អ្នកដឹកនាំ" គឺជាមនុស្សដែលគេមានការទុកចិត្តកក់ក្តៅ ហើយអាចជឿបាន លក្ខណៈទីពីរការចេះដឹងយល់សាច់ការដឹកនាំសង្គម និងមនុស្សលក្ខណៈទី៣ គឺការដែលចង់ជួយយកអាសារអ្នកដ៏ទៃមិនប្រកាន់ ហើយមានគម្រោងប្រសើរសំរាប់អនាគតល្អរបស់សហគមន៍ខ្លួន ។ នៅ ស.រ.អា នេះ "មេ-ដឹកនាំ" គេបានឱ្យគំរូប្លែកៗនឹងគួរគោរព ភាពឆ្លាតវៃនៃវីរជនទាំងនោះ គឺមិនត្រឹមតែចេះធ្វើល្អធ្វើឱ្យរីកចំរើនតែប៉ុណ្ណោះទេ សូម្បីតែទំនាស់ដ៏ធំធេងនៃសង្គម ដូចជា ការប្រកាន់ពណ៌សំបុរស្បែក ក៏ "មេដឹកនាំ" គេអាចកែច្នៃឱ្យទៅជាវិជ្ជមានមកវិញបានយ៉ាងងាយស្រួល ។ នៅមានករណីធ្ងន់ធ្ងរនៃសេដ្ឋកិច្ចអាមេរិកាំង គេពុំឃើញមានសហគមន៍អាមេរិកាំង រង់ចាំឱបដៃចោទប្រកាន់ថា អាក្រក់ ឬអញបានធ្វើល្អនោះទេ គេប្រមូលកម្លាំងប្រជាជាតិទាំងមូលឱ្យក្លាយជាសម្បត្តិជាតិជាឋាមពលរដ្ឋរួមគ្នាប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ចយ៉ាងរឹងប៉ឹងបាន ។ លក្ខណៈសម្បត្តិសំខាន់មួយទៀតនោះ គឺ"មេដឹកនាំ "នៃ ស.រ.អ នេះ គេដឹកនាំមនុស្សឱ្យបានទៅដល់គោលដៅដែលប្រជាជាតិគេចង់បាន ពុំមែនជាគោលដៅរបស់ប្រយោជន៍ផ្ទាល់ខ្លួននោះទេ ។

គោលបំណងនៃអត្ថបទ "ថ្នាក់ដឹកនាំ"នេះ ចង់ឱ្យលោកអ្នកអានប្រៀបធៀបទៅថ្នាក់ដឹកនាំខ្មែរយើងថា "មេដឹកនាំ"ណាខ្លះ ដែលមានបុគ្គលិកលក្ខណៈ ដូច"មេដឹកនាំ" នៃ ស.រ.អា នេះ ។ តាំងពីសម្តេច សីហនុ ដល់ លន់នល់ ពី ប៉ុល ពត ដល់ ប៉ែន សុវណ្ណ ពី ហ៊ុន សែន ដល់ ទ្រង់ រណឫទ្ធិ នៅមានមេដឹកនាំបំរុងពីររូបទៀត គឺលោក សម រង្ស៊ី និងលោក កឹម សុខា តើតួរអង្គណាមួយដែលរាប់បានថា "មេដឹកនាំ" គំរូលំនាំ "មេដឹកនាំ" ស.រ.អា នេះ ។

ប្រជាពលរដ្ឋខ្មែរ គួរប្តូរគំនិតជ្រើសរើស "មេដឹកនាំ" ដែលគ្រាន់តែមានលុយ មានកាំភ្លើង មានបុព្វសិទ្ធ នោះចោលចេញ ហើយជ្រើសរើសរកដោយការស្គាល់បុគ្គលិកលក្ខណៈល្អរបស់បុគ្គលនោះជំនួសវិញ ៕

MANN Since 1909
Funeral Home, INC.
219 West Tabor Road .
Philadelphia, PA 19120
(215) 458-3282
Henry S. Mann 1915-1993 | H.Craig Mann Supervesor | Frederick mann, Jr. Founder
A CENTURY of Excellence to the Delaware Valley
Proudly serving Asian Communities for over 48 years.
ឈាបនដ្ឋាន
"ម៉ែន"
➪ បម្រើសហគមនតាំង៣១០០ឆ្នាំមកហើយ មានទីកន្លែងសមរម្យធ្វើពិធីតម្កល់សព ។
➪ មានក្តារមឈូសអាចបូជា ឬបញ្ចុះសព នៅ ២០ឆ្នាំចុងក្រោយនេះ យើងមានសេវាបម្រើសហគមន៍ខ្មែរ ឱ្យអាចធ្វើបុណ្យតាមប្រពៃណីជូនដំណើរអ្នកដែលបានចែកឋានទៅ ។
បើសិនមានសំណួរ សូមទាក់ទងទៅ :
Craig MANN : (215) 548-3292

តមកពីទំព័រទី១៤

## គណបក្សប្រជាជន...

ហើយត្រូវបានចុះចូលជាមួយរដ្ឋាភិបាលនាគ្រាកន្លងមកនេះ ។ ក្រៅពីនោះក៏នៅមានមន្ត្រីអមដំណើរ ដូចជាលោក អ៊ិត សីលា និងសមាជិកសមាជិការបស់សាខាគណបក្សប្រជាជនកម្ពុជា



ប្រចាំនៅទីក្រុងហ្វីឡាដែលហៀជាច្រើនរូបទៀត ។

ទោះបីជាកម្មវិធីបានប្រព្រឹត្តិដោយបរិយាកាសសប្បាយរីករាយ និងយ៉ាងល្អរលូនព្រមទាំងមានកិច្ចការពារផ្នែកសន្តិសុខបានយ៉ាងល្អក្តី តែអ្នកគាំទ្រ និងអ្នកចូលរួមហាក់មានចំនួនដ៏តិចតួចនៅឡើយ ។

ស្ត្រីចូលរួមម្នាក់មកពីទីក្រុងហ្វីឡាដែលហៀខាងត្បូងដែលសុំមិនបញ្ចេញឈ្មោះ និងមិនអនុញ្ញាតឱ្យថតរូបភាព បានប្រាប់ខ្មែរប៉ុស្តិ៍ថា ឱកាសនោះថា នាងមានការភ្ញាក់ផ្អើលណាស់ នៅពេលដែលនាងបានចូលរួមក្នុងកម្មវិធីរៃអង្គាសប្រាក់ នារាត្រីនោះ ព្រោះមានភ្ញៀវតិចតួចណាស់បានចូលរួម ហើយតុនៅទំនេរជាច្រើន ។

ស្ត្រីរូបនោះបានដាក់ជាចម្ងល់ថា ចុះហេតុអ្វីបានជាគណៈកម្មការរៀបចំកម្មវិធីស្ទើរតែទាំងអស់ សុទ្ធតែពាក់ស្លាកសញ្ញារបស់គណបក្សប្រជាជនជាសំគាល ? ឬមួយជាពិធីជប់លៀងរបស់គណបក្សប្រជាជន ដោយគ្រាន់តែយកឈ្មោះប្រមូលថវិកាទៅជួយទាហាននៅតំបន់ប្រាសាទព្រះវិហារជាខែល ? ។

ប្រធានគណៈកម្មការរៀបចំអង្គពិធីលោក សុខ យុទ្ធ បានឱ្យខ្មែរប៉ុស្តិ៍ ដឹងថា : ទឹកប្រាក់ដែលប្រមូលបានពីសប្បុរសជននារាត្រីនោះមានចំនួនជាងបួនពាន់ដុល្លារ សម្រាប់យកទៅជួយដល់យុទ្ធជនដែលកំពុងការពារបូរណភាពទឹកដីខ្មែរ ដែលកំពុងឈរជើងនៅប្រាសាទព្រះវិហារ ជាពិសេសនៅសមភូមិវាលឥន្ទ្រីយ៍តែម្តង ៕



ហាងម្ចាស់ នួន វីដេអូ សូមស្វាគមន៍
នាឱកាសចូលឆ្នាំថ្មី 2009
មានលក់ CD VCD & DVD
MCHAS NOUN VIDEO
647 RITNER ST. PHILADELPHIA, PA 19148
Tel : (215) 465-0464




យើងខ្ញុំមានលក់សំលៀកបំពាក់ប្រពៃណីខ្មែរ និងម៉ូដទាន់សម័យសំរាប់ចូលរួមពិធីផ្សេងៗមាន CD ,DVD និងមានរបស់របរច្រើនមុខទៀត ។





ប្រសិនបើសំលៀកបំពាក់ដែលបងប្អូនទិញ ហើយពាក់មិនត្រូវទេ យើងអាចកែរជូនដោយឥតយកកំរៃ យើងក៏មានទទួលកាត់ដេរខោ និងកែសម្រួលសំលៀកបំពាក់ដែលលោកអ្នកនាំមកពីក្រៅហាង យើងខ្ញុំដោយយកតម្លៃសមរម្យ ។

## Khmermarket Phone Cards



**Special Rate for Cambodia, Vietnam & Laos**
**Order by Phone 267-475-9694**
**for cell phone & and landline**
**No connection fee, No expired, No surcharge**
**Call one minute count one minute 4 cent p/m**

**$10 =250mins, $20 = 520mins, $30 = 770 mins,$40=1030 mins**
**Address: 302 w Somerville Ave, Philadelphia, PA 19120**
**Email: order@khmermarket.biz**
**Website: www.khmermarket.biz/prepaidphonecard.html**

## ឱសថស្ថានខ្មែរ

Sav-Mor PHARMACY Tel: 215-467-1220

Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



### បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត

- Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
- យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ

*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

## ដំណឹងរកអ្នកធ្វើការ

"វេដ ម៉េឌីខលសេនធ័រ" រកអ្នកធ្វើការច្រើននាក់ចេះនិយាយភាសាខ្មែរមានកំរិតសិក្សាថ្នាក់ "អនុបណ្ឌិតខាងព្យាបាលសុខភាពផ្លូវចិត្ត"។ ធ្វើការយកកំរៃតាមពេលមកធ្វើការក៏បាន ឬពេញម៉ោងក៏បាន ។ ធ្វើការនៅតំបន់ ឡូហ្គាន់ និងនៅហ្វីឡាដែលហៀខាងត្បូងជាមួយនឹងអ្នកជំងឺ ដែលត្រូវការព្យាបាលខាងជំងឺផ្លូវចិត្ត ។

**សូមផ្ញើប្រវត្តិរូបតាមលិខិតឆ្មួតាទៅ :**

LORI WATSON @1939 SOUTH JUNIPER STREET
PHILADELPHIA, PA 19148

The Wedge Medical Center is seeking the Cambodian-speaking Master's Level Mental Health Therapists for the Logan and South Philadelphia Sites to provide Outpatient Mental Health Therapy (Fee-For-Service or Full Time). All Interested Candidates should 'regular mail' their resumes to LORI WATSON @ 1939 South Juniper Street, Philadelphia, PA 19148.

## គណបក្សសិទ្ធិមនុស្ស

បំរើ-ការពារ-កសាង
**HUMAN RIGHTS PARTY**



### ដឹកនាំដោយឯកឧត្តម កឹម សុខា

សូមអញ្ជើញលោក.លោកស្រីមើលក្នុងគេហទំព័រ www.HRPCambodia.info ដើម្បីស្តាប់វិទ្យុ និងតាមដានព័ត៌មានទាន់សភាពការណ៍ ទាក់ទងនឹងប្រទេសកម្ពុជា ។
បើអស់លោកចង់ចូលរួម សូមទាក់ទងមក

លោក ញ៉ាយ ចំរើន តួរស័ព្ទ :
267-226-7861 អ៊ីម៉ែល : chamroeunkh@yahoo.com

# ទឹកភ្នែកស្ត្រីខ្មែរកម្ពុជាក្រោមហូរស្រក់ក្នុងអង្គការសហប្រជាជាតិ

*New York*, **ខ្មែរប៉ុស្តិ៍ : មាជ សុណ្ណារ៉ា**

●●●ស្ត្រីម្នាក់តំណាងយុវជនរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមបានធ្លាយទឹកភ្នែកហូរស្រក់ប្រកបដោយក្តីក្តុកក្តួលខ្សឹបខ្សួលក្នុងខណៈឡើងថ្លែងទៅកាន់សន្និសីទវេទិកាជនជាតិដើមរបស់អង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក កាលពីថ្ងៃទី 27 ខែឧសភា កន្លងទៅនេះ ក្នុងន័យថា "នៅកម្ពុជាក្រោម គឺគ្មានត្រូវការអ្វីក្រៅពីចង់រស់នៅឱ្យមានអត្តសញ្ញាណជាខ្មែរ និងគោរពប្រតិបត្តិតាមលំនាំវប្បធម៌ប្រពៃណីខ្មែរនោះឡើយ" ។

ថ្លែងប្រាប់កាសែតខ្មែរប៉ុស្តិ៍តាមរយៈទូរស័ព្ទពីទីស្នាក់ការអង្គការសហប្រជាជាតិនៅបូរីញូវយ៉ក អ្នកស្រី ថាច់ សុម៉ាលីន បានឱ្យដឹងថា "នៅទីនោះខ្ញុំបានលើកជាសំណូមពរទៅកាន់អ្នកស្រីប្រធានសន្និសីទវេទិការជនជាតិដើម និងការរំលឹកឱ្យដឹងពីប្រវត្តិជូរចត់របស់ខ្ញុំដែលបានរត់ចេញពីមាតុភូមិកម្ពុជាក្រោមជាមួយឪពុកម្តាយរបស់នាងខ្ញុំ ដោយសារតែប្រព័ន្ធគ្រប់គ្រងក្រុងហាណូយបានបែងចែកពលរដ្ឋតាមភាពខុសគ្នានៃអត្តសញ្ញាណជាខ្មែរក្រោម និងការកាន់វប្បធម៌ខុសពីគេរបស់ខ្ញុំប៉ុណ្ណោះ" ។ "ខ្ញុំមិនចង់បានអ្វីក្រៅពីសិទ្ធិរស់នៅក្នុងស្រុកកំណើតរបស់ខ្ញុំនោះឡើយ ដូចបុព្វបុរសរបស់ខ្ញុំដែលនិយាយភាសាដើមរបស់ខ្ញុំ ដែលយើងជាខ្មែរកម្ពុជាក្រោមមានជំនឿខ្លាំងក្លាថា វាគួរដល់ពេលហើយដែលវៀតណាមត្រូវតែឈប់បដិសេធសិទ្ធិរបស់យើងក្នុងការថ្លាថ្លែងនាវេទិកានេះ ដោយចាប់ផ្តើមអនុវត្តនូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិដូចមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួនផ្ទាល់ និងធម្មនុញ្ញអង្គការសហប្រជាជាតិ " ។

អ្នកស្រី ថាច់ សុម៉ាលីន និយាយថា ទោះបីយួនមិនទទួលស្គាល់ខ្មែរថា ជាជនជាតិដើមក៏ដោយ ក៏ពួកយើងជាខ្មែរកម្ពុជាក្រោមនៅតែបន្តការតស៊ូតវ៉ាតាមបែបអហិង្សាប្រយុទ្ធប្រឆាំងដើម្បីសិទ្ធិសេរីភាព ក្នុងនាមជាម្ចាស់ទឹកដីនៃជនជាតិដើមខ្មែរកម្ពុជាក្រោម ដែលមិនមែនជាជនជាតិភាគតិចដូចយួនបានអះអាងនោះទេ ដោយយើងជាក្រុមយុវវ័យជំនាន់ក្រោយនឹងប្រឹងប្រែងរំដោះយកសិទ្ធិសេរីភាពក្នុងផ្នែកសិទ្ធិមនុស្ស និងការគោរពលទ្ធិប្រជាធិបតេយ្យ លទ្ធិជំនឿសាសនា ការរក្សាតម្លៃវប្បធម៌ក្នុងនាមជាជនជាតិខ្មែរកម្ពុជាក្រោមឱ្យទាល់តែបានក្នុងទីបញ្ចប់មួយតាមរយៈអង្គការសហព័ន្ធខ្មែរកម្ពុជាក្រោម ដែលយើងត្រូវតែក្រោកឡើងរួបរួមគ្នាក្នុងការតវ៉ាប្រឆាំងជាមួយរដ្ឋអំណាចយួនដែលបានប៉ុនប៉ងចង់រំលាយពូជសាសន៍ខ្មែរយើងជាច្រើនសតវត្សមកហើយនោះ ។




អ្នកស្រី ថាន់ ម៉ាលីន បានអំពាវនាវសុំឱ្យយុវជន-យុវនារីខ្មែរកម្ពុជាក្រោមនៅក្រៅប្រទេសនាំខ្មែរឱ្យរួមធ្វើការដើម្បីរំដោះសិទ្ធិសេរីភាព ដោយពុំឱ្យឪពុកម្តាយជួយជំរុញកម្លាំងចិត្តពួកគេជួយធ្វើការពីបញ្ហានេះ សូមកុំខ្លាច និងកុំអស់ជំនឿ ដោយគិតថា យួនខ្លាំងមិនអាចឈ្នះគេបានទេ គឺយើងមិនអាចទៅមុខបានទេ បើគិតយ៉ាងដូច្នេះ ។ ហើយឆ្លៀតឱកាសនេះអ្នកស្រី សុម៉ាលីន ក៏បានស្នើសុំឱ្យរដ្ឋាភិបាល ហ៊ុន សែន គួរគិតពិចារណាថា ខ្មែរកម្ពុជាក្រោម ក៏ជាខ្មែរដែរ មិនមែនជាជនជាតិយួនទេ ក្នុងការរើសអើងពូជសាសន៍ខ្មែរគ្នាឯងព្រោះតម្រូវ និងយកចិត្តគាប់គុណជាតិសាសន៍គេទៅវិញនោះ ? ។

ក្រុមតំណាងម្ចាស់ប្រទេសជនជាតិដើម ដែលបានបាត់បង់ដីធ្លី បាននាំគ្នាចាប់អារម្មណ៍ពីសុន្ទរកថារបស់អ្នកស្រី រហូតមានអ្នកខ្លះទប់ចិត្តមិនបានបង្ហូរទឹកភ្នែកតាមដោយមិនដឹងខ្លួន ពីការយកចិត្តទុកដាក់ខ្លាំងពីក្រុមបរទេសដែលបានចូលរួមទៀតផង ។

នាយកប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម លោក ថាច់ ង៉ុកថាច់ បានមានប្រសាសន៍ថា "លោកស្រីនាយកនៃអង្គប្រជុំបានចាប់អារម្មណ៍

(តទៅទំព័រទី ១៨)




